តាំង $A$ ជាម៉ាទ្រីសកុំផ្លិច នោះមានធាតុមួយយ៉ាងតិចជាធាតុកុំផ្លិច។ បើ $Z=a+bi$ គឺជាចំនួនកុំផ្លិចនោះ $\overline{Z}=a-bi$ ចំនួនកុំផ្លិចឆ្លាស់។ $A=\left[a_{ij}\right]$ ជាម៉ាទ្រីសកុំផ្លិច $\overline{A}=\left[b_{ij}\right]$ ជាម៉ាទ្រីសកុំផ្លិចឆ្លាស់ ដែល $b_{ij}=\overline{a_{ij}}$ ។ ចំណាំ $A^H=\left(\overline{A}\right)^T=\overline{A^T}$

ឧទាហរណ៍១៥ មាន $A=\begin{bmatrix}2-8i & -6\\ 5+3i & 1+4i\\ 4+7i & 3-2i\end{bmatrix}$ $\Rightarrow A^H=\begin{bmatrix}2+8i & 5-3i & 4-7i\\ 6i & 1-4i & 3+2i\end{bmatrix}$

## ១៣. ប្លុកម៉ាទ្រីស

ឧទាហរណ៍១ គេមានម៉ាទ្រីស

$$A=\begin{bmatrix}3 & 0 & -1 & 5 & 9 & -2\\ -5 & 2 & 4 & 0 & -3 & 1\\ -8 & -6 & 3 & 1 & 7 & -4\end{bmatrix}$$

$$A=\left[\begin{array}{ccc|cc|c} 3 & 0 & -1 & 5 & 9 & -2 \\ -5 & 2 & 4 & 0 & -3 & 1 \\ \hline -8 & -6 & 3 & 1 & 7 & -4 \end{array}\right] \text{ គេបាន } A=\begin{bmatrix} A_{11} & A_{12} & A_{13} \\ A_{21} & A_{22} & A_{23} \end{bmatrix}$$

$$A_{11}=\begin{bmatrix} 3 & 0 & -1 \\ -5 & 2 & 4 \end{bmatrix}, \quad A_{12}=\begin{bmatrix} 5 & 9 \\ 0 & -3 \end{bmatrix}, \quad A_{13}=\begin{bmatrix} -2 \\ 1 \end{bmatrix}$$

$$A_{21}=\begin{bmatrix} -8 & -6 & 3 \end{bmatrix}, \quad A_{22}=\begin{bmatrix} 1 & 7 \end{bmatrix}, \quad A_{23}=\begin{bmatrix} -4 \end{bmatrix}$$

ម៉ាទ្រីសខាងលើនេះត្រូវបានគេហៅថា ប្លុកម៉ាទ្រីស

ឧទាហរណ៍២ ឧទាហរណ៍ប្រសិនបើបន្ទះសៀគ្វីកុំព្យូទ័រខ្នាតតូចមានមីក្រូឈីប VLSI(រួមបញ្ចូលគ្នាក្នុងទ្រង់ទ្រាយធំ) បន្ទាប់មកម៉ាទ្រីសសម្រាប់បន្ទះសៀគ្វីអាចមានទម្រង់ទូទៅ



$$A=\left[\begin{array}{c|c|c} A_{11} & A_{12} & A_{13} \\ \hline A_{21} & A_{22} & A_{23} \\ \hline A_{31} & A_{32} & A_{33} \end{array}\right]$$

### ផលគុណនៃម៉ាទ្រីសប្លុក

ឧបមាថា $U=U_{ik}$ និង $V=V_{kj}$ គឺជាប្លុកម៉ាទ្រីសដែលចំនួនជួរឈរនៃប្លុក $U_{ik}$ នីមួយៗស្មើនឹងចំនួនជួរដេកនៃប្លុក $V_{kj}$ នីមួយៗ ។ (ដូច្នេះផលិតផលនីមួយៗ $U_{ik}V_{kj}$ ត្រូវបានកំណត់)។

$$UV=\begin{bmatrix} W_{11} & W_{12}\dots\dots\dots W_{1n} \\ W_{21} & W_{22}\dots\dots\dots W_{2n} \\ \dots & \dots\dots \quad \dots\dots \\ W_{m1} & W_{m2}\dots\dots\dots W_{mn} \end{bmatrix}$$

$$W_{ij}=U_{i1}V_{1j}+U_{i2}V_{2j}+\dots+U_{ip}V_{pj}$$

ឧទាហរណ៍៣ គេមានប្លុកម៉ាទ្រីស

$$A=\left[\begin{array}{ccc|cc} 2 & -3 & 1 & 0 & -4 \\ 1 & 5 & -2 & 3 & -1 \\ \hline 0 & -4 & -2 & 7 & -1 \end{array}\right]=\begin{bmatrix} A_{11} & A_{12} \\ A_{21} & A_{22} \end{bmatrix} \text{ និង } B=\left[\begin{array}{cc} 6 & 4 \\ -2 & 1 \\ -3 & 7 \\ \hline -1 & 3 \\ 5 & 2 \end{array}\right]=\begin{bmatrix} B_1 \\ B_2 \end{bmatrix}$$

ផលគុណ $AB=\begin{bmatrix}A_{11} & A_{12}\\ A_{21} & A_{22}\end{bmatrix}\begin{bmatrix}B_1\\ B_2\end{bmatrix}=\begin{bmatrix}A_{11}B_1+A_{12}B_2\\ A_{21}B_1+A_{22}B_2\end{bmatrix}$

ដោយ $A_{11}B_1=\begin{bmatrix}2 & -3 & 1\\ 1 & 5 & -2\end{bmatrix}\begin{bmatrix}6 & 4\\ -2 & 1\\ -3 & 7\end{bmatrix}=\begin{bmatrix}15 & 12\\ 2 & -5\end{bmatrix}$

$$A_{12}B_2=\begin{bmatrix}0 & -4\\ 3 & -4\end{bmatrix}\begin{bmatrix}-1 & 3\\ 5 & 2\end{bmatrix}=\begin{bmatrix}-20 & -8\\ -8 & 7\end{bmatrix}$$

$$A_{11}B_1+A_{12}B_2=\begin{bmatrix}15 & 12\\ 2 & -5\end{bmatrix}+\begin{bmatrix}-20 & -8\\ -8 & 7\end{bmatrix}=\begin{bmatrix}-5 & 4\\ -6 & 2\end{bmatrix}$$

ហើយ $A_{21}B_1=\begin{bmatrix}0 & -4 & -2\end{bmatrix}\begin{bmatrix}6 & 4\\ -2 & 1\\ -3 & 7\end{bmatrix}=\begin{bmatrix}14 & -18\end{bmatrix}$

$$A_{22}B_2=\begin{bmatrix}7 & -1\end{bmatrix}\begin{bmatrix}-1 & 3\\ 5 & 2\end{bmatrix}=\begin{bmatrix}-12 & 19\end{bmatrix}$$

$$A_{21}B_1+A_{22}B_2=\begin{bmatrix}14 & -18\end{bmatrix}+\begin{bmatrix}-12 & 19\end{bmatrix}=\begin{bmatrix}-2 & 1\end{bmatrix}$$

ដូចនេះ $AB=\begin{bmatrix}A_{11} & A_{12}\\ A_{21} & A_{22}\end{bmatrix}\begin{bmatrix}B_1\\ B_2\end{bmatrix}=\begin{bmatrix}A_{11}B_1+A_{12}B_2\\ A_{21}B_1+A_{22}B_2\end{bmatrix}=\begin{bmatrix}-5 & 4\\ -6 & 2\\ -2 & 1\end{bmatrix}$

# ជំពូកទី១ វ៉ិចទ័រក្នុង $\mathbb{R}^n$ និង $\mathbb{C}^n$, ទំហំវ៉ិចទ័រ

## ១.១. សេចក្តីផ្តើម

មានវិធីពីរយ៉ាងក្នុងការកំណត់សញ្ញាណនៃវ៉ិចទ័រ ដែលទី១គឺជាតុនៃចំនួននិងតាងអក្សរតូច ហើយទី២ នោះគឺតាងដោយតម្លៃដាក់លាក់នៅក្នុងរូបវិទ្យា។ យើងនឹងពិភាក្សាវិធីទាំងពីរនេះដូចខាងក្រោម។

### ១.១.១. ធាតុនៃចំនួន

ឧបមាថាទម្ងន់របស់សិស្សប្រាំបីនាក់បានចុះបញ្ជីដូចខាងក្រោម( គិតជាផោន )៖

156, 125, 145, 134, 178, 145, 162, 193

ជាដំបូងយើងតាងបញ្ជីនៃតម្លៃទាំងអស់ខាងលើដោយនិមិត្តសញ្ញា $w$ និងតម្លៃជាតុនីមួយៗដោយនិមិត្តសញ្ញា $w_1, w_2, w_3.........w_8$ ដែលមានជាតុនីមួយៗមានតម្លៃត្រូវគ្នានឹងជាតុ

$$w_1 = 156, w_2 = 125, w_3 = 145.........w_8 = 193$$

ដូចនេះ ជាតុរបស់តម្លៃទាំងអស់យើងកំណត់សរសេរ៖

$w = (w_1, w_2, w_3, ........., w_n)$ ហៅថា ជួរពីជគណិត ឬវ៉ិចទ័រ *( linear array or vector)* ។

### ១.១.២. វ៉ិចទ័រក្នុងរូបវិទ្យា

មានបរិមាណរូបវន្តជាច្រើនដូចជាសីតុណ្ហភាពនិងល្បឿនរបស់វាមានត្រឹមតែ *"អាំងតង់ស៊ីតេ"* ប៉ុណ្ណោះ ហើយអាចត្រូវបានតំណាងដោយចំនួនពិត ហើយត្រូវបានគេហៅថា ទំហំស្កាលែ។ម្យ៉ាងវិញទៀត ក៏មានបរិមាណដូចជាកម្លាំង និងល្បឿន ដែលមានទាំងពីរគឺ *"អាំងតង់ស៊ីតេ"* និង *"ទិសដៅ"* ។ បរិមាណទាំងនេះ ដែលអាចត្រូវបានតំណាងដោយព្រួញដែលមានប្រវែង និងទិសដៅសមស្រប ហើយចេញមកពីមួយចំនួនដែលបានផ្តល់ឱ្យចំណុចគល់ O ត្រូវបានគេហៅថា *វ៉ិចទ័រ។*

ឥឡូវនេះយើងសន្មត់ថាអ្នកអានស្គាល់ចន្លោះ $\mathbb{R}^3$ ដែលចំណុចទាំងអស់នៅក្នុងលំហត្រូវបានតំណាងដោយគូលំដាប់ចំនួនបីនៃចំនួនពិត។ ឧបមាថាប្រភពដើមនៃអ័ក្សក្នុង $\mathbb{R}^3$ ត្រូវបានជ្រើសរើសជាចំណុចគល់ O សម្រាប់វ៉ិចទ័រដែលបានពិភាក្សាខាងលើ បន្ទាប់មកវ៉ិចទ័រនីមួយៗត្រូវបានកំណត់ដោយឯកឯងដោយកូអរដោនេរបស់វាចំណុចចុង និងច្រាសមកវិញ។

មានប្រមាណវិធីសំខាន់ពីរគឺ ការបូកពីរវ៉ិចទ័រ និងទំហំស្កាលែ ដែលភ្ជាប់ជាមួយវ៉ិចទ័រនៅក្នុងរូបវិទ្យា។







( ក ) ផលបូកនៃវ៉ិចទ័រ រូបភាព ១.១ ( ខ ) ផលគុណស្កាលែ

## ១.២. វ៉ិចទ័រក្នុង $\mathbb{R}^n$

សំណុំនៃ $n$ វិមាត្រ ទាំងអស់របស់ចំនួនពិតត្រូវបានកំណត់ដោយ $R^n$ ហើយត្រូវបានហៅថា $n$-លំហរ ($n$-space)។ $n$ វិមាត្រពិសេសមួយនៅក្នុង $R^n$ ដែលកំណត់ដោយ ៖

$u=(a_1,a_2,...,a_n)$ ដែលត្រូវបានហៅថា *ចំណុច ឬវ៉ិចទ័រ* ( *point or vector* )។

ដែល $a_i$ គឺជា កូអរដោនេ សមាសភាគ(កំប៉ូសង់) ឬជាធាតុរបស់ $\mathbb{R}^n$។ ហើយលើសពីនេះទៅទៀត នៅពេលដែលយើងពិភាក្សាពីលំហរ $\mathbb{R}^n$ ។

វ៉ិចទ័រពីរ $u$ និង $v$ គឺស្មើគ្នា សរសេរ $u=v$ ប្រសិនបើពួកវាមានចំនួនសមាសធាតុដូចគ្នា ហើយធាតុដែលត្រូវគ្នាគឺស្មើគ្នា។

ឧទាហរណ៍វ៉ិចទ័រ $(1,2,3)$ និង $(3,2,1)$ មានចំនួនសមាសធាតុដូចបីដូចគ្នា។ប៉ុន្តែ វ៉ិចទ័រទាំងនេះមិនស្មើគ្នាទេ ព្រោះធាតុដែលត្រូវគ្នាមិនស្មើគ្នា។

វ៉ិចទ័រ $(0,0,.....0)$ ដែលជាធាតុទាំងអស់គឺ $0$ ត្រូវបានគេហៅថាវ៉ិចទ័រសូន្យ ហើយជាធម្មតាត្រូវបានតំណាងដោយ $O$ ។

ឧទាហរណ៍១

(ក) ទាំងនេះគឺជាវ៉ិចទ័រ $v_1=(2,-5),\ \ v_2=(7,9),\ \ v_3=(0,0,0),\ \ v_4=(3,4,5)$

ដែលវ៉ិចទ័រ $v_1,v_2$ ជារបស់ $R^2$

វ៉ិចទ័រ $v_3,v_4$ ខាងក្រោយជារបស់ $R^3$ ។

$v_3$ គឺជាវ៉ិចទ័រសូន្យដែលនៅក្នុង $R^3$ ។

(ខ) រក $x,y,z$ ដែល $(x-y,\ \ x+y,\ \ z-1)=(4,2,3)$។

ចម្លើយ

ដោយប្រើនិយមន័យរបស់សមភាពនៃវ៉ិចទ័រដែលធាតុទាំងអស់ត្រូវតែស្មើគ្នា។

$(x-y,\ \ x+y,\ \ z-1)=(4,2,3)$

$x-y=4$

$x+y=2$

$z-1=3$

ដោយឆ្លងកាត់ការដោះស្រាយប្រព័ន្ធសមីការខាងលើគេបានចម្លើយ

$x=3,\quad y=-1, z=4$

### ១.២.១ វ៉ិចទ័រជួរឈរ

ពេលខ្លះវ៉ិចទ័រនៅក្នុង $R^n$ គឺភាគច្រើនត្រូវបានសរសេរជារាងបញ្ឈរ *(Vertically)* ជាជាងរាងផ្តេក *(Horizontally)* ។ វ៉ិចទ័រនោះត្រូវបានហៅថា វ៉ិចទ័រជួរឈរ *(Column Vector)* ។ ជាមួយគ្នានេះដែរ ក្នុងឧទាហរណ៍១.១ វ៉ិចទ័រដែលត្រូវបានសរសេរជារាងផ្តេកហៅថាវ៉ិចទ័រជួរដេក *(Row Vector)*។ ជាឧទាហរណ៍ខ្លះខាងក្រោមនេះជាវ៉ិចទ័រជួរឈរដែលមានជាតុរៀងគ្នាដូចខាងក្រោម៖

$$\begin{bmatrix}1\\2\end{bmatrix},\ \begin{bmatrix}3\\-4\end{bmatrix},\ \begin{bmatrix}1\\5\\-6\end{bmatrix},\ \begin{bmatrix}1.5\\ \frac{2}{3}\\-15\end{bmatrix}$$

យើងក៏អាចចំណាំបានថាចំពោះប្រមាណវិធីដែលកំណត់ចំពោះវ៉ិចទ័រជួរដេកគឺមានភាពស្រដៀងគ្នាទៅនឹងវ៉ិចទ័រជួរឈរផងដែរ។

## ១.៣.ផលបូកវ៉ិចទ័រ និងផលគុណស្កាលែ

គេមានវ៉ិចទ័រពីរ $u$ និង $v$ ក្នុង $R^n$ ដែលកំណត់សរសេរដោយ $u=(a_1,a_2,...,a_n)$ និង $v=(b_1,b_2,...,b_n)$ ហើយផលបូកនៃវ៉ិចទ័រទាំងពីរត្រូវបានសរសេរជា $u+v$ មានន័យថាគឺជាការបូកគ្រប់ជាតុត្រូវគ្នាពី $u$ ទៅ $v$ គេបាន៖

$$u+v=(a_1+b_1,a_1+b_2,......,a_n+b_n)$$




ផលគុណស្កាលែរនៃវ៉ិចទ័រ $u=(a_1,a_2,...,a_n)$ ដោយចំនួនពិត $k$ គេសរសេរ $ku$ គឺមានន័យថាគុណគ្រប់ជាតុរបស់ $u$ ដោយមេគុណ $k$ គេបាន៖

$$ku=k(a_1,a_2,...,a_n)=(ka_1,ka_2,...,ka_n)$$

ឧទាហរណ៍១.២

(ក) តាង $u=(2,4,-5)$ និង $v=(1,-6,9)$ ។

គណនា $u+v,\ \ 7u,\ \ -v$ និង $3u-5v$

ចម្លើយ

គណនា $u+v,\ \ 7u,\quad -v$ និង $3u-5v$

$$u+v=(2+1,\ 4+(-6),\ -5+9)=(3,-2,4)$$
$$7u=(7(2),\ 7(4),\ 7(-5))=(14,\ 28,-35)$$
$$-v=(-1)(1,\ 6,\ -9)=(-1,6,-9)$$
$$3u-5v=(6,12,-15)+(-5,30,-45)=(1,42,-60)$$

( ខ ) វ៉ិចទ័រសូន្យ $0=(0,0,\dots,0)$ នៅក្នុង $\mathbb{R}^n$ គឺដូចគ្នាទៅនឹងតម្លៃ 0 ហើយចំពោះវ៉ិចទ័រ $u=(a_1,a_2,\dots,a_n)$ ណាមួយ។

$$u+0=(a_1+0,\ a_2+0,\dots,a_n+0)=(a_1,\ a_2,\dots,a_n)=u$$

( គ ) តាង $u=\begin{bmatrix}2\\3\\-4\end{bmatrix}$ និង $v=\begin{bmatrix}3\\-1\\-2\end{bmatrix}$ ។ នោះគេបាន $2u-3v=\begin{bmatrix}4\\6\\8\end{bmatrix}+\begin{bmatrix}-9\\3\\6\end{bmatrix}=\begin{bmatrix}-5\\9\\-2\end{bmatrix}$ ។

**ទ្រឹស្តីបទ១.១** ចំពោះវ៉ិចទ័រ $u,v,w$ ដែលនៅក្នុង $R^n$ និងមេគុណស្កាលែ $k,k'$ នៅក្នុង $R$ គេបាន

$(i)\ \ (u+v)+w=u+(v+w),\qquad (v)\ \ k(u+v)=(ku+kv),$

$(ii)\ \ u+0=u,\qquad (vi)\ \ (k+k')u=ku+k'u,$

$(iii)\ \ u+(-u)=0,\qquad (vii)\ \ (kk')u=k(k'u),$

$(iv)\ \ u+v=v=u,\qquad (viii)\ 1u=u$

## ១.៤. ផលគុណចំណុច ( ស្កាលែ )

ឧបមាថាវ៉ិចទ័រ $u$ និង $v$ ក្នុង $R^n$ ដែលកំណត់សរសេរដោយ $u=(a_1,a_2,\dots,a_n)$ និង $v=(b_1,b_2,\dots,b_n)$ នោះគេបានផលគុណចំណុច ឬផលគុណខាងក្នុង ឬផលគុណស្កាលែនៃវ៉ិទ័រ $u$ និង $v$ គឺត្រូវបានសម្គាល់ និងកំណត់ដោយ

$$u\cdot v=(a_1\cdot b_1+\ a_2\cdot b_2+\ \dots+a_n\cdot b_n)$$

គឺមានន័យថាជាការគុណគ្រប់ធាតុដែលត្រូវគ្នារួចហើយធ្វើការបូកបញ្ចូលគ្នាដើម្បីបានចម្លើយជាចំនួនពិត។

វ៉ិចទ័រ $u$ និង $v$ អរត្តូកូណាល់លុះត្រាផលគុណចំណុច( ផលគុណស្កាលែ )ស្មើសូន្យ។ គេសរសេរៈ

$$u\cdot v=0\Leftrightarrow u\perp v$$

ឧទាហរណ៍១.៣

( ក ) តាង $u=(1,-2,3),\ v=(4,5,-1),\ w=(2,7,4)$ ។

គេបាន $u\cdot v=1(4)-2(5)+3(-1)=4-10-3=9$

$u\cdot w=2-14+12=0$

$v\cdot w=8+35-4=39$

ដូចនេះ $u$ និង $w$ អរតូកូណាល់គ្នា។

( ខ ) តាង $u=\begin{bmatrix}2\\3\\-4\end{bmatrix}$ និង $v=\begin{bmatrix}3\\-1\\-2\end{bmatrix}$ ។

គេបាន $u\cdot v=2(3)+3(-1)+(-4)(-2)=6-3+8=11$ ។

( គ ) ឧបមា $u=(1,2,3,4),\ v=(6,k,-8,2)$ ។ កំណត់តម្លៃ $k$ ដើម្បីអោយ $u$ និង $v$ អរតូកូណាល់គ្នា។

គេបាន $u\cdot v=6+2k-24+8=-10+2k$

$u$ និង $v$ អរតូកូណាល់គ្នាលុះត្រាតែ $u\cdot v=0$ គេបាន $-10+2k=0\Rightarrow k=5$ ។

**ទ្រឹស្តីបទ១.២** ចំពោះវ៉ិចទ័រ $u,v,w$ ដែលនៅក្នុង $R^n$ និងមេគុណស្កាលែ $k,k'$ នៅក្នុង $R$ គេបាន

$(i)\quad (u+v)\cdot w=u\cdot w+v\cdot w,\qquad (iii)\quad u\cdot v=v\cdot u$

$(ii)\quad (ku)\cdot v=k(u\cdot v)\qquad (vi)\quad u\cdot u\geq 0,$ ហើយ $u\cdot u=0\Leftrightarrow u=0$

### ១.៤.១. ណមនៃវ៉ិចទ័រ

ណម ឬប្រវែងនៃវ៉ិចទ័រ $u=(a_1,a_2,\dots,a_n)$ មួយត្រូវបានសម្គាល់ដោយ $\|u\|$ គឺមានន័យថាឬសការេនៃ $u\cdot u$ ។ ជាឧទាហរណ៍ប្រសិនបើ $u=(a_1,a_2,\dots,a_n)$ គេបាន៖

$$\|u\|=\sqrt{u\cdot u}=\sqrt{a_1^2+a_2^2+\dots+a_n^2}$$

$\|u\|$ គឺមានន័យថាឬសការេនៃផលបូកការេនៃធាតុរបស់ $u$ ។

ដូចនេះ $\|u\|\geq 0$ ហើយ $\|u\|=0$ លុះត្រាតែ $u=0$ ។

វ៉ិចទ័រ $v$ មួយជាវ៉ិចទ័រហៅថាវ៉ិចទ័រឯកតាលុះត្រាតែ $\|u\|=1$ ឬក៏ $u\cdot u=1$ ។ ចំពោះវ៉ិចទ័រមិនសូន្យ $v$ នៅក្នុង $R^n$ គេបាន $\hat{v}=\frac{1}{\|v\|}v=\frac{v}{\|v\|}$

គឺជាវ៉ិចទ័រឯកតា *(Unique Unit Vector)* ដែលមានទិសដៅដូចទៅនឹងវ៉ិចទ័រ $v$ ។

ឧទាហរណ៍១.៣

(ក) ឧបមាថា $u=(1,-2,-4,5,3)$ រកតម្លៃ $\|u\|$

ចម្លើយ

ជាដំបូងយើងត្រូវរក $\|u\|^2=u\cdot u$ ដោយលើកការេធាតុនីមួយៗរបស់ $u$ រួចបូកបញ្ចូលគ្នាដូចខាងក្រោម៖

$$\|u\|^2=1^2+(-2)^2+(-4)^2+5^2+3^2=1+4+16+25+9=55$$

គេបាន $\|u\| = \sqrt{55}$

(ខ) តាង $v=(1,-3,4,2)$ និង $w=\left(\frac{1}{2},-\frac{1}{6},\frac{5}{6},\frac{1}{6}\right)$ ។រកតម្លៃ $\|v\|$ និង $\|w\|$ រួចពិនិត្យមើលរកវ៉ិចទ័រឯកតា។

ចម្លើយ

គេបាន $\|v\| = \sqrt{1+9+16+4} = \sqrt{30}$, $\|w\| = \sqrt{\frac{9}{36}+\frac{1}{36}+\frac{25}{36}+\frac{1}{36}} = \sqrt{\frac{36}{36}} = \sqrt{1} = 1$

ដូចនេះ $w$ គឺជាវ៉ិចទ័រឯកតាប៉ុន្តែ $v$ មិនមែនទេ។

យើងអាចធ្វើការរក $\hat{v}$ ដូចខាងក្រោម

$$\hat{v} = \frac{v}{\|v\|} = \left(\frac{1}{\sqrt{30}},\frac{-3}{\sqrt{30}},\frac{4}{\sqrt{30}},\frac{2}{\sqrt{30}}\right)$$ គឺជាវ៉ិចទ័រឯកតាដឹលមានទិសដៅដូចទៅនឹង $v$ ។

**ទ្រឹស្តីបទ១.៣** (Schwarz) ៖ ចំពោះវ៉ិចទ័រ $u,v$ ក្នុង $R^n, |u\cdot v| \le \|u\|\cdot\|v\|$ ។

សម្រាយបញ្ជាក់

គ្រប់ចំនួនពិត $t$ ហើយនឹងទ្រឹស្តីបទ១.២ យើងបាន

$$0 \le (tu+v)\cdot(tu+v) = t^2(u\cdot u)+2t(u+v)+(v\cdot v) = \|u\|^2 t^2 + 2(u\cdot v)t + \|v\|^2$$

តាង $a=\|u\|^2$, $b=2(u\cdot v)$, $c=\|v\|^2$ នោះកន្សោមខាងលើក្លាយជា

$$at^2+bt+c \ge 0 \qquad \text{គ្រប់តម្លៃ } t \text{ ។}$$

មានន័យថា សមីការមិនអាចមានឫសពីរជាចំនួនពិតទេ ដែល

$$\Delta = b^2-4ac \le 0$$

$$b^2 \le 4ac$$

$$[2(u\cdot v)]^2 \le 4\|u\|^2\|v\|^2$$

$$\left[4(u\cdot v)^2\right] \le 4\|u\|^2\|v\|^2$$

$$(u\cdot v)^2 \le \|u\|^2\|v\|^2$$

$$u\cdot v \le \|u\|\cdot\|v\|$$

**ទ្រឹស្តីបទ១.៤** (Minkoweski) ៖ចំពោះវ៉ិចទ័រ $u,v$ $in R^n, \|u+v\| \le \|u\|+\|v\|$ ។

សម្រាយបញ្ជាក់

តាមវិសមភាព Schwarz និង លក្ខណៈផលគុណស្កាលែ

$$\|u+v\|^2=(u+v)\cdot(u+v)=(u\cdot u)+2(u\cdot v)+(v\cdot v)\leq\|u\|^2+2\|u\|\cdot\|v\|+\|v\|^2=(\|u\|+\|v\|)^2$$

$$\|u+v\|^2\leq(\|u\|+\|v\|)^2$$

$$\|u+v\|\leq\|u\|+\|v\|$$

## ១.៤.២. ចម្ងាយ មុំ និងចំណោល

- ចម្ងាយរវាងវ៉ិចទ័រ $u=(a_1)$ និង $v=(b_1)$ នៅក្នុង $R$ គឺត្រូវបានសម្គាល់ និងកំណត់សរសេរដោយៈ

$$d(u,v)=\|u-v\|=\sqrt{(a_1-b_1)^2}=|a_1-b_1|$$




- ចម្ងាយរវាងវ៉ិចទ័រ $u=(a_1,a_2)$ និង $v=(b_1,b_2)$ នៅក្នុង $R^2$ គឺត្រូវបានសម្គាល់ និងកំណត់សរសេរដោយៈ

$$d(u,v)=\|u-v\|=\sqrt{(a_1-b_1)^2+(a_2-b_2)^2}$$

- ចម្ងាយរវាងវ៉ិចទ័រ $u=(a_1,a_2,a_3)$ និង $v=(b_1,b_2,b_3)$ នៅក្នុង $R^3$ គឺត្រូវបានសម្គាល់ និងកំណត់សរសេរដោយៈ

$$d(u,v)=\|u-v\|=\sqrt{(a_1-b_1)^2+(a_2-b_2)^2+(a_3-b_3)^2}$$

- ចម្ងាយរវាងវ៉ិចទ័រ $u=(a_1,a_2,...,a_n)$ និង $v=(b_1,b_2,...,b_n)$ នៅក្នុង $R^n$ គឺត្រូវបានសម្គាល់ និងកំណត់សរសេរដោយៈ

$$d(u,v)=\|u-v\|=\sqrt{(a_1-b_1)^2+(a_2-b_2)^2+...+(a_n-b_n)^2}$$

- មុំ $\theta$ រវាងវ៉ិចទ័រមិនសូន្យ $u,v$ នៅក្នុង $R^n$ គឺត្រូវបានកំណត់ដោយ

$$\text{Cos}\,\theta=\frac{u\cdot v}{\|u\|\|v\|}$$ ។

ការកំណត់នេះគឺត្រឹមត្រូវដោយផ្អែកលើវិសមភាពSchwarz ទ្រឹស្តីបទ១.៣ គេបាន

$$-1\leq\frac{u\cdot v}{\|u\|\|v\|}\leq 1$$

- ចំណោលកែង *(Projection)* នៃវ៉ិចទ័រ $u$ ទៅលើវ៉ិចទ័រមិនសូន្យ $v$ ត្រូវបានសម្គាល់ និង កំណត់ដោយ៖ $proj(u,v)=u^*=\frac{u\cdot v}{\|v\|^2}v=\frac{u\cdot v}{v\cdot v}v$

ពិនិត្យវ៉ិចទ័រ $u,v$ ក្នុងរូប 1-2a ដែលមាន $u^*$ ជាចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$ ជាមួយទំហំ

$\|u^*\|=\|u\|\cdot\cos\theta$ រូបមន្ត $\cos\theta=\frac{OC}{OA}=\frac{\|u^*\|}{\|u\|}$

$$\|u^*\|=\|u\|\cdot\frac{u\cdot v}{\|u\|\cdot\|v\|}=\frac{u\cdot v}{\|v\|}$$

ដោយវ៉ិចទ័រ $u^*=\|u^*\|\cdot\hat{v}=\|u^*\|\cdot\frac{v}{\|v\|}$ តែ $\|u^*\|=\frac{u\cdot v}{\|v\|}$ យកជំនួសកន្សោមខាងលើយើងទទួលបាន

$$u^*=\frac{u\cdot v}{\|v\|}\cdot\frac{v}{\|v\|}=\frac{u\cdot v}{\|v\|^2}\cdot v$$

ដូចនេះ ទៅនិយមន័យខាងលើនៃចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$ គឺ $u^*$ មានរូបមន្ត៖

$$u^*=\frac{u\cdot v}{\|v\|}\cdot\frac{v}{\|v\|}=\frac{u\cdot v}{\|v\|^2}\cdot v$$




រូបភាព 1-2a

## ឧទាហរណ៍១

(ក) ឧបមាថា $u=(1,-2,3),\ v=(2,4,5)$ ។

១.គណនាចម្ងាយពីវ៉ិចទ័រ $u$ មកវ៉ិចទ័រ $v$

២.រកតម្លៃ $\cos\theta=\cos(u,v)$

៣.រកចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$

ចម្លើយ

១.គណនាចម្ងាយពីវ៉ិចទ័រ $u$ មកវ៉ិចទ័រ $v$

គេបាន $d(u,v)=\|u-v\|=\sqrt{(1-2)^2+(-2-4)^2+(3-5)^2}=\sqrt{1+36+4}=\sqrt{41}$

២.រកតម្លៃ $\cos\theta=\cos(u,v)$

ដើម្បីរក $\cos\theta$ ដែលជាមុំផ្គុំឡើងរវាង $u$ និង $v$ ដំបូងយើងត្រូវរក

$$u\cdot v=2-8+15=9,\quad \|u\|^2=1+4=9=14,\quad \|v\|^2=4+16+25=45$$

គេបាន $\cos\theta=\dfrac{u\cdot v}{\|u\|\|v\|}=\dfrac{9}{\sqrt{14}\sqrt{45}}$

៣.រកចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$

$$proj(u,v)=u^*=\frac{u\cdot v}{\|v\|^2}v=\frac{9}{45}(2,4,5)=\frac{1}{5}(2,4,5)=\left(\frac{2}{5},\frac{4}{5},1\right)$$

ឧទាហរណ៍២ ឧបមាថា $u=(1,-3,4)$ និង $u=(3,4,7)$ ។

១.រកតម្លៃ $\cos\theta$ ដែលមុំ $\theta=(u,v)$

២. រកចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$

៣.គណនាចម្ងាយពីវ៉ិចទ័រ $u$ មកវ៉ិចទ័រ $v$

ចម្លើយ

ដំបូងយើងរកតម្លៃ

$u.v=3-12+28=19$

$\|u\|^2=1+9+16=26$

$\|v\|^2=9+16+49=74$

១.រកតម្លៃ $\cos\theta$ ដែលមុំ $\theta=(u,v)$

យើងបាន $\cos\theta=\dfrac{u.v}{\|u\|.\|v\|}=\dfrac{19}{\sqrt{26}.\sqrt{74}}$

២. រកចំណោលនៃវ៉ិចទ័រ $u$ មកលើវ៉ិចទ័រ $v$

យើងបាន $proj(u.v)=u^*=\dfrac{u.v}{\|v\|^2}\cdot v=\dfrac{19}{74}\cdot(3,4,7)=\left(\dfrac{57}{74},\dfrac{76}{74},\dfrac{133}{74}\right)=\left(\dfrac{57}{74},\dfrac{38}{37},\dfrac{133}{74}\right)$

៣.គណនាចម្ងាយពីវ៉ិចទ័រ $u$ មកវ៉ិចទ័រ $v$

យើងបាន $d(u,v)=\|u-v\|=\sqrt{(3-1)^2+(4+3)^2+(7-4)^2}=\sqrt{4+49+4}=\sqrt{62}$

## ១.៥. វ៉ិចទ័រទីតាំង ប្លង់ បន្ទាត់ និង ខ្សែកោងក្នុង $R^n$

### ១.៥.១.វ៉ិចទ័រទីតាំង

គូរខ្លះនៃចំណុច $A(a_i)$ និង $B(b_i)$ ក្នុង $R^n$ កំណត់វ៉ិចទ័រទីតាំង ឬអង្កត់មានទិសដៅកាត់ពី $A$ ទៅ $B$ យើងកំណត់សរសេរ $\overrightarrow{AB}$ ។មានរូបមន្តកំណត់ដោយវ៉ិចទ័រ $\overrightarrow{AB}$ ៖

$$\overrightarrow{AB}=|B-A|=[b_1-a_1,b_2-a_2,....,b_n-a_n]$$

ព្រោះ $\overrightarrow{AB}$ និង $u$ មានទំហំ និងទិសដៅដូចគ្នា ។ ក្នុងរូបភាព1-2b សម្រាប់ចំណុច $A=(a_1,a_2,a_3)$ និង $B=(b_1,b_2,b_3)$ ក្នុង $R^n$ ហើយនឹងវ៉ិចទ័រ $u=\overrightarrow{AB}$ ដែលមានចំណុចចុង

$$P=(b_1-a_1,b_2-a_2,b_3-b_3)$$




*រូបភាព 1-2b*

ឧទាហរណ៍១៖

ចូររកតម្លៃវ៉ិចទ័រ $v$ ដែលបង្កើតដោយអង្កត់មានទិសដៅ $\overrightarrow{PQ}$ តាមចំណុចខាងក្រោម៖

a. $P(2,3,-6)$; $Q(1,-6,-5)$

b. $P(1,-8,-4,6)$; $Q(3,-5,2,-4)$

ចម្លើយ

រកតម្លៃវ៉ិចទ័រ $v$ ដែលបង្កើតដោយអង្កត់មានទិសដៅ $\overrightarrow{PQ}$ តាមចំណុច

a. $P(2,3,-6)$; $Q(1,-6,-5)$

$$\Rightarrow \quad v=\overrightarrow{PQ}=(1-2,-6-3,-5-(-6))=(-1,-9,1)$$

b. $P(1,-8,-4,6)$; $Q(3,-5,2,-4)$

$$\Rightarrow \quad v=\overrightarrow{PQ}=(3-1,-8-(-8),2-(-4),-4-6)=(2,0,8,-10)$$

## ១.៥.២. សមីការប្លង់



ប្លង់ $H$ មួយក្នុង $R^3$ គឺសំណុំចំណុច $(x_1,x_2,x_3)$ ដែលបំពេញលក្ខខណ្ឌសមីការលីនេអ៊ែរ

$(H): a_1x_1+a_2x_2+a_3x_3=d$ ហៅថា **សមីការទូទៅរបស់ប្លង់**

$(H): a_1(x_1-p_1)+a_2(x_2-p_2)+a_3(x_3-p_3)=0$ **សមីការស្តង់ដារ**

ដែលមានវ៉ិចទ័រណរម៉ាល់មិនសូន្យ $u=(a_1,a_2,a_3)$ ហើយមានចំណុចកាត់ $P(p_1,p_2,p_3)$ ដែលមានតម្លៃ $d=a_1p_1+a_2p_2+a_3p_3$ ដូចរូបខាងក្រោម៖

ហើយប្លង់ $H$ មួយក្នុង $R^n$ គឺសំណុំចំណុច $(x_1,x_2,.....x_n)$ ដែលបំពេញលក្ខខណ្ឌសមីការលីនេអ៊ែរ៖

$(H): a_1x_1+a_2x_2+.....+a_nx_n=d$ គឺជា **សមីការទូទៅរបស់ប្លង់ក្នុង** $R^n$

$(H): a_1(x_1-p_1)+a_2(x_2-p_2)+.....+a_n(x_n-p_n)=0$ គឺជា **សមីការស្តង់ដាររបស់ប្លង់**

ដែលមានវ៉ិចទ័រណរម៉ាល់មិនសូន្យ $u=(a_1,a_2,a_3,......a_n)$ហើយមានចំណុចកាត់$P(p_1,p_2,p_3,....p_n)$ ។ ដូចគ្នានេះដែរប្លង់ $H$ មួយក្នុង $R^2$ គឺសំណុំចំណុច $(x,y)$មានទម្រង់ជា **សមីការទូទៅរបស់បន្ទាត់។**

ឧទាហរណ៍១

$a.$ គេឲ្យ $H$ ជាប្លង់ក្នុង $R^3$ ដែលត្រូវគ្នានឹងសមីការនីលីអ៊ែរ $2x-5y+7z=4$ និងមានវ៉ិចទ័រណរម៉ាល់ $u=(2,-5,7)$ ។

ក. បង្ហាញថា $2x-5y+7z=4$

ខ. បង្ហាញ $u$ កែង $\overrightarrow{PQ}$

ចម្លើយ

ក. បង្ហាញថា $P(1,1,1)$ និង $Q(5,4,2)$ ជាចំនុចស្ថិតក្នុងប្លង់

មានប្លង់ $2x-5y+7z=4$ បើ $P(1,1,1)$ និង $Q(5,4,2)$ ជាចំនុចស្ថិតក្នុងប្លង់ នោះផ្ទៀងផ្ទាត់សមភាព

ករណី $P(1,1,1)$ គេបាន $2\cdot1-5\cdot1+7\cdot1=4 \quad \Leftrightarrow 4=4$ ពិត

ករណី $Q(5,4,2)$ គេបាន $2\cdot5-5\cdot4+7\cdot2=4 \quad \Leftrightarrow 4=4$ ពិត

ខ. បង្ហាញ $u$ កែង $\overrightarrow{PQ}$

មាន $u=(2,-5,7)$

យើងបាន $\overrightarrow{PQ}=Q-P=(5-1,4-1,2-1)=(4,3,1)$

នៅលើប្លង់H ។វ៉ិចទ័រ $u=[2,-5,7]$ គឺកែងនឹងH និងដូចរំពឹងទុក

$$u\cdot v=[2,-5,7]\cdot[4,3,1]=8-15+7=0$$

នោះវ៉ិចទ័រ u គឺ កែងទៅវ៉ិចទ័រ v ។

(b) រកសមីការនៃ hyperplane H ក្នុង $\mathbf{R}^4$ ដែលឆ្លងកាត់ចំណុច $P(1,3,-4,2)$ ហើយកែងវ៉ិចទ័រ $u=[4,-2,5,6]$ ។

មេគុណអញ្ញាត នៃសមីការ Hគឺសមាសភាគកាត់វ៉ិចទ័រu ដូចនេះសមីការនៃ H ត្រូវតែជាទម្រង់

$$4x_1-2x_2+5x_3+6x_4=k$$

ការជំនួស P ក្នុងសមីការនេះ យើងទទួលបាន

$$4(1) - 2(3) + 5(-4) + 6(2) = k \text{ ឬ } 4 - 6 - 20 + 12 = k \text{ ឬ } k = -10$$

ដូច្នេះ $4x_1 - 2x_2 + 5x_3 + 6x_4 = -10$ គឺសមីការនៃ H

### ១.៥.៣. បន្ទាត់ក្នុង $R^n$

បន្ទាត់ L ក្នុង $R^n$ ឆ្លងកាត់ចំណុច $P(b_1, b_2, \dots, b_n)$ និងក្នុងទិសដៅនៃវ៉ិចទ័រ nonzero

$$u = [a_1, a_2, \dots, a_n]$$

កើតមានឡើងនៃចំណុច$X(x_1, x_2, \dots, x_n)$ដែលបំពេញលក្ខខណ្ឌ

$$X = P + tu \text{ ឬ } \begin{cases} x_1 = a_1 t + b_1 \\ x_2 = a_2 t + b_2 \\ \dots\dots\dots\dots\dots\dots. \\ x_n = x_n t + b_n \end{cases} \text{ ឬ } L(t) = (a_1 t + b_1)$$

ដែលប៉ារ៉ាម៉ែត្រt យកតម្លៃពិតទាំងអស់ ដូចបន្ទាត់ Lក្នុង$R^3$ គឺរូបភាព ក្នុងរូប ។




(c) រកប៉ារ៉ាម៉ែត្រ តំណាងនៃបន្ទាត់ L ក្នុង $\mathbf{R^4}$ ឆ្លងកាត់ចំណុច $P(1, 2, 3, -4)$ ហើយក្នុងទិសដៅនៃ $u = [5, 6, -7, 8]$ ។ រកចំណុច Q លើ L ពេល $t = 1$

ការជំនួសក្នុងសមីការខាងលើសម្រាប់ទិន្ន័យ L តាមប៉ារ៉ាម៉ែត្រតំណាង :

$$x_1 = 5t + 1 \quad x_2 = 6t + 2 \quad x_3 = -7t + 3 \quad x_4 = 8t - 4$$

ឬ សមមូល ។

$$L(t) = (5t + 1, 6t + 2, -7t + 3, 8t - 4)$$

ចំណាំថា $t = 0$ ទិន្ន័យ ចំណុច P លើL ។ការជំនួសនៃ $t = 1$ ទិន្ន័យចំណុច $Q(6, 8, -4, 4)$លើ L ។

### ១.៦. វ៉ិចទ័រក្នុង$R^3$

វ៉ិចទ័រក្នុង $\mathbf{R^3}$ បានហៅចន្លោះវ៉ិចទ័រ កើតឡើងក្នុងការអនុវត្តន៍ជាច្រើន ជាពិសេសក្នុងរូបវិទ្យា ។ជាការពិតណាស់និមិត្តសញ្ញាសម្គាល់ពិសេសគឺជាញឹកញ៉ាប់បានប្រើសម្រាប់វ៉ិចទ័រដូចខាងក្រោម:

$i = [1, 0, 0]$ បោះបង់ចោលវ៉ិចទ័រឯកតាក្នុងទិសដៅ x

$j = [0, 1, 0]$ បោះបង់ចោលវ៉ិចទ័រឯកតាក្នុងទិសដៅ y

$k = [0, 0, 1]$ បោះបង់ចោលវ៉ិចទ័រឯកតាក្នុងទិសដៅ $z$

បន្ទាប់មក វ៉ិចទ័រ $u = [a, b, c]$ ក្នុង$\mathbf{R}^3$ មួយចំនួនអាចបានបញ្ជាក់តែមួយក្នុងទម្រង់

$u = [a, b, c] = ai + bj + ck$

ព្រោះវ៉ិចទ័រ $i, j, k$ គឺវ៉ិចទ័រឯកតា ហើយគឺ orthogonal ទៅវិញទៅមក យើងទទួលបានផលគុណស្កាលែរ ដូចខាងក្រោម:

$$i \cdot i = 1, j \cdot j = 1, k \cdot k = 1 \text{ និង } i \cdot j = 0, i \cdot k = 0, j \cdot k = 0$$

លើសពីនេះទៅទៀត ប្រមាណវិធីវ៉ិចទ័របានពិភាក្សាខាងលើ ប្រហែលបានបញ្ជាក់ក្នុង និមិត្តសញ្ញា ijk ដូចខាងក្រោម ។

សន្មត់

$u = a_1 i + a_2 j + a_3 k$ និង $v = b_1 i + b_2 j + b_3 k$

បន្ទាប់មក

$u \cdot v = (a_1 + b_1)i + (a_2 + b_2)j + (a_3 + b_3)k$ និង $cu = ca_1 i + ca_2 j + ca_3 k$

ដែល$c$គឺស្កាលែរមួយ ។

$u \cdot v = a_1 b_1 + a_2 b_2 + a_3 b_3$ និង $\|u\| = \sqrt{u \cdot v} = a_1^2 + a_2^2 + a_3^2$

ឧទាហរណ៍ 1.8 ឧបមា$u = 3i + 5j - 2k$ និង $v = 4i - 8j + 7k$ ។

(a)រក$u + |v$ បន្ថែមសមាសធាតុដែលត្រូវគ្នា ទទួលបាន $u + v = 7i - 3j + 5k$

(b)រក$3u - 2v$ គុណលេខដំបូងដោយស្កាលែរ និងបន្ថែម

$$3u - 2v = (9i + 13j - 6k) + (-8i + 16j - 14k) = i + 29j - 20k$$

(c) រក$u \cdot v$ គុណលេខសមាសធាតុដែលត្រូវគ្នា ហើយបន្ទាប់មកបន្ថែម:

$$u \cdot v = 12 - 40 - 14 = -42$$

(d) រក$\|u\|$ ឬសការេនៃផលបូកនៃការេនៃសមាសធាតុ$\|u\| = \sqrt{9 + 25 + 4} = \sqrt{38}$

## ១.៦.១.ផលគុណវ៉ិចទ័រ

ផលគុណវ៉ិចទ័រនៃវ៉ិចទ័រគឺដូចខាងក្រោម:

សន្មត់ថា$u = a_1 i + a_2 j + a_3 k$ និង$v = b_1 i + b_2 j + b_3 k$បន្ទាប់មក $i \times j, = k\, j \times k = i, k \times i = j$

$u \times v = (a_2 b_3 - a_3 b_2)(a_3 b_1 - a_1 b_3)(a_1 b_2 - a_2 b_1)$ $i \times j, = -k\, j \times k = -i, k \times i = -j$

$$= \begin{vmatrix} a_1 & = a_2 & a_3 \\ b_1 & = b_2 & b_3 \end{vmatrix} i - \begin{vmatrix} a_1 & = a_2 & a_3 \\ b_1 & = b_2 & b_3 \end{vmatrix} j + \begin{vmatrix} a_1 & = a_2 & a_3 \\ b_1 & = b_2 & b_3 \end{vmatrix} k$$

នេះគឺជា បីសមាសធាតុ នៃ$u \times v$ គឺបានទទួលពីលំដាប់ជួរ

$$\begin{bmatrix} a_1 & a_2 & a_3 \\ b_1 & b_2 & b_3 \end{bmatrix}$$

(ដែលបញ្ចូលសមាសសធាតុនៃ $u$ ខាងលើសមាសធាតុនៃ $v$) ដូចខាងក្រោម:

(1) គ្របគ្នាជួរឈរទីមួយ និងយកដេទែមីណង់

(2) គ្របគ្នាជួរឈរទីពីរ និងយកអវិជ្ជមាននៃដេទែម៉ណង់

(3) ត្រួតគ្នាជួរឈរទីបី និងយកដេទែមីណង់

ចំណាំថា $u \times v$ គឺវ៉ិចទ័រមួយ ដូចនេះ $u \times v$ គឺតែងតែបានហៅផលគុណវ៉ិចទ័រ ឬផលគុណខាងក្រៅនៃ $u$ និង$v$ ។

ឧទាហរណ៍1.9 រក $u \times v$ ដែល:(a)$u = 4i + 3j + 6k, v = 2i + 5j - 3k$, (b)$u = [2, -1, 5]$, $v = [3, 7, 6]$ ។

(a) ប្រើ$\begin{bmatrix} 4 & 3 & 6 \\ 2 & 5 & -3 \end{bmatrix}$ដើម្បីបាន $u \times v = (-9 - 30)i + (12 + 12)j + (20 - 6)k$
$= -39i + 24j + 14k$

(b) ប្រើ$\begin{bmatrix} 2 & -1 & 5 \\ 3 & 7 & 6 \end{bmatrix}$ដើម្បីបាន $u \times v = [-6 - 35, 15 - 12, 14 + 3] = [-41, 3, 17]$

**ទ្រឹស្តីបទ** ឲ្យ$u, v, w$ ជាវ៉ិចទ័រក្នុង $\mathbf{R}^3$

(a) វ៉ិចទ័រ $u \times v$ គឺorthogonal ទៅទាំងពីរ $u$ផង និង$v$ផង

(b) តម្លៃដាច់ខាតនៃ" ត្រីគុណ"

$\|u \cdot (v \times w)\|$

តំណាងឲ្យ មាឌនៃប្រលេពីប៉ែតដោយវ៉ិចទ័រ $u, v, w$




ចំណាំ៖

វ៉ិចទ័រ $u, v, u \times v$ ទម្រង់ប្រព័ន្ធដៃស្តាំមួយ ហើយរូបមន្តខាងក្រោមនោះផ្តល់ទំហំនៃ$u \times v$ :

$\|u \times v\| = \|u\|.\|v\|.\sin\theta$ ដែល$\theta$ គឺមុំនៅចន្លោះ $u$ និង $v$




## ១.៧. ចំនួនកុំផ្លិច

សំណុំនៃចំនួនកុំផ្លិចគឺបានចង្អុលប្រាប់ដោយ **C** ។ ជាផ្លូវការចំនួនកុំផ្លិចមួយគឺនៃលំដាប់គូរមួយ $(a, b)$ នៃចំនួនពិតដែលសមភាព លេខបូក និងលេខគុណ គឺបានកំណត់ខាងក្រោម៖

$(a,b) = (c,d)$ បើសិនលក្ខខណ្ឌចាំបាច់ $a = c$ និង $b = d$
$(a,b) + (c,d) = (a+c, b+d)$
$(a,b) \cdot (c,d) = (ac - bd, ad - bc)$

យើងកំណត់អត្តសញ្ញាណចំនួនពិតមួយ ជាមួយចំនួនកុំផ្លិច$(a,0)$ នោះគឺ

$a \leftrightarrow (a,0)$

នេះគឺអាចកើតឡើង ព្រោះប្រមាណវិធីនៃ លេខបូក និងលេខគុណនៃចំនួនពិត បានបម្រុងទុកខាងក្រោម ភាពត្រូវគ្នាទាំងនេះ

$(a,0) + (b,0) = (a+b, 0)$ និង $(a,0) \cdot (b,0) = (ab, 0)$

ដូច្នេះយើងមើល **R** ដូចជាសំណុំរងនៃ**C** ហើយជំនួស $(a,0)$ដោយ a ទោះបីងាយស្រួល និងអាចទៅរួច ។

យើងចំណាំថាសំណុំ **C** នៃចំនួនកុំផ្លិចជាមួយប្រមាណវិធីខាងលើ ណៃលេខបូក និងលេខគុណ គឺដែលនៃចំនួន ដូចសំណុំ **R** នៃចំនួនពិត និងសំណុំ **Q** នៃចំនួនសនិទាន ។

ចំនួនកុំផ្លិច $(0,1)$ គឺត្រូវបានផ្តល់ដោយ $i$។ វាក៏មានលក្ខណៈពិសេសដែរ គឺ

$i^2 = ii = (0,1)(0,1) = (-1,0) = -1$ រឺ $i = \sqrt{-1}$

លើសពីនេះទៀត ចំនួនកុំផ្លិចផ្សេងទៀតដែល $z = (a,b)$ អាចសរសេរនៅក្នុងទម្រង់

$$z = (a,b) = (a,0) + (0,b) = (a,0) + (b,0).(0,1) = a + bi$$

ការកំណត់ខាងលើ $z = a + bi$ ដែល $a = \text{Re}\, z$ ត្រូវបានគេហៅថា ផ្នែកពិត និង $b = \text{Im}\, z$ ផ្នែកនិមិត្តនៃ $Z$ គឺតាងដោយ $(a,b)$។ តាមពិត ផលបូកនិងផលគុណនៃចំនួនកុំផ្លិចច្រើន $z = a + bi$ និង $w = c + di$ អាចត្រូវបានទាញយកដោយច្បាប់វិធានបំបែកនិងលក្ខណៈត្រឡប់ដែលប្រើប្រាស់សាមញ្ញ ហើយនិង $i^2 = -1$ ។

$$z + w = (a+bi) + (c+di) = a + c + bi + di = (a+c) + (b+d)i$$
$$zw = (a+bi)(c+di) = ac + bci + adi + bdi^2 = (ac - bd) + (bc + ad)i$$

យើងក៏បានកំណត់ភាពអវិជ្ជមាននៃ $z$ និងផលដកនៅក្នុង $C$ ដោយ

$-z = -1z$ និង $w - z = w + (-z)$

## ១.៧.១. កុំផ្លិចឆ្លាស់ តម្លៃដាច់ខាត

ចូរគិតពិចារណាពីចំនួនកុំផ្លិច $z = a + bi$ ។ ភាពឆ្លាស់នៃ $z$ គឺតាងនិងកំណត់ដោយ $\bar{z} = \overline{a+bi} = a - bi$ នោះ $z\bar{z} = (a+bi)(a-bi) = a^2 - b^2i^2 = a^2 + b^2$ ។ ចំណាំ $z$ គឺពិតលុះត្រាតែ $\bar{z} = z$។

តម្លៃដាច់ខាតនៃ $z$ តាងដោយ $|z|$ គឺកំណត់បានថាជាឫសការេមិនអវិជ្ជមាននៃ $\bar{z}z$ ។ គេសរសេរបានថា ។ $|z| = \sqrt{z\bar{z}} = \sqrt{a^2 + b^2}$

ចំណាំ $|z|$ គឺស្មើទៅនឹងណមនៃវ៉ិចទ័រ $(a,b)$នៅក្នុង $R^3$។

ឧបមាថា $z \neq 0$ ។ នោះភាពច្រាសនៃ $z$ គឺ $z^{-1}$ និងការចែកនៅក្នុង $C$ នៃ $w$ ដោយ $z$ ត្រូវបានគេអោយដោយ $z^{-1} = \frac{\bar{z}}{z\bar{z}} = \frac{a}{a^2+b^2} - \frac{b}{a^2+b^2} i$ និង $\frac{w}{z} - \frac{w\bar{z}}{z\bar{z}} = wz^{-1}$

ឧទាហរណ៍១ ឧបមាថា $z=2+3i$ និង $w=5-2i$។ នោះ

$z+w=(2+3i)+(5-2i)=2+5+3i-2i=7+i$

$zw=(2+3i)(5-2i)=10+15i-4i-6i^2=16+11i$

$\frac{w}{z}=\frac{5-2i}{2+3i}=\frac{(5-2i)(2-3i)}{(2+3i)(2-3i)}=\frac{4-19i}{13}=\frac{4}{13}-\frac{19}{13}i$

$|z|=\sqrt{4+9}=\sqrt{13},|w|=\sqrt{25+4}=\sqrt{29}$

## ១.៨. វ៉ិចទ័រនៅក្នុង $C^n$

គ្រប់សំណុំ $n$-tuple នៃចំនួនកុំផ្លិច ត្រូវបានតាងដោយ $C^n$ គឺត្រូវបានគេហៅថាកុំផ្លិចលំហ $n$ ។ គ្រាន់នៅក្នុងករណីផ្នែកពិត ដែលគ្រប់ធាតុនៃ $C^n$ គឺត្រូវគេហៅថាជាចំណុចដ៏ច្រើនឬក៏ជាវ៉ិចទ័រ ដែលធាតុនៃ $C$ ត្រូវបានគេហៅថាស្កាលែ ហើយការបូកវ៉ិចទ័រនិងការគុណស្កាលែនៅលើ $C^n$ គេឱ្យដោយ

$[z_1,z_2,...,z_n]+[w_1,w_2,...,w_n]=[z_1+w_1,z_2+w_2,...,z_n+w_n]$

$z[z_1,z_2,...,z_n]=[zz_1,zz_2,...,zz_n]$

ដែល $z_i,w_i$ និង $z$ ជារបស់ $C$ ។

ឧទាហរណ៍១ ចូរគណនាវ៉ិចទ័រ $u=(2+3i,4-i,3)$ និង $v=(3-2i,5i,4-6i)$ នៅក្នុង $C^3$ ។ នោះ

$v+u=(2+3i,4-i,3)+(3-2i,5i,4-6i)=(5+i,4+4i,7-6i)$

$(5-2i)u=[(5-2i)(2+3i),(5-2i)(4-i),(5-2i)(3)]=(16+11i,18-13i,15-6i)$

### ១.៨.១. ផលគុណស្កាលែរ (ផលគុណក្នុង) នៅក្នុង $C^n$

ចូរគណនាវ៉ិចទ័រ $u=[z_1,z_2,...,z_n]$ និង $w=[w_1,w_2,...,w_n]$ នៅក្នុង $C^n$ ។ ផលគុណចំណុចឬក្នុងនៃ $u$ និង $v$ គឺត្រូវបានតាងនិងកំណត់ដោយ

$u.v=z_1\overline{w_1}+z_2\overline{w_2}+...+z_n\overline{w_n}$

និយមន័យនេះបានប្តូរទៅជាករណីផ្នែកពិតផ្សេងទៀតព្រោះ $\overline{w_i}=w_i$ នៅពេលដែល $w_i$ ជាផ្នែកពិត។ ណមនៃ $u$ កំណត់ដោយ $|u|=\sqrt{u.u}=\sqrt{z_1\overline{z_1}+z_2\overline{z_2}+...+z_n\overline{z_n}}=\sqrt{|z_1|^2+|z_2|^2+...+|z_n|^2}$

យើងបញ្ជាក់ថា $u.u$ និងដូច្នេះ $|u|$ គឺវិជ្ជមាន ពេលដែល $u\neq 0$ ហើយ $0$ ពេលដែល $u=0$ ។

ឧទាហរណ៍ ១ ចូរគណនាវ៉ិចទ័រ $u=(2+3i,4-i,3+5i)$ និង $v=(3-4i,5i,4-2i)$ នៅក្នុង $C_3$ ។ នោះ

$u.v=(2+3i)(\overline{3-4i})+(4-i)(\overline{5i})+(3+5i)(\overline{4-2i})=(2+3i)(3+4i)+(4-i)(-5i)+(3+5i)(4+2i)$

$=(-6+13i)+(-5-20i)+(2+26i)=-9+19i$

$u.u=|2+3i|^2+|4-i|^2+|3+5i|^2=4+9+16+1+9+25=64$

$|u|=\sqrt{64}=8$

# ជំពូកទី២ ផលគុណស្កាលែរ

## ២.០. រំលឹកនិងបន្ថែម៖ អនុវត្តលីនេអ៊ែរ

គេមាន $E$ និង $E'$ ពីរលំហវ៉ិចទ័រលើកាយ $\mathbb{K}$ តែមួយ និង $f$ ជាអនុវត្តមួយពី $E$ ទៅ $E'$ ។
គេថា $f$ ជា**អនុវត្តលីនេអ៊ែរ**បើ៖
1) ចំពោះគ្រប់ $u, v \in E, f(u+v) = f(u) + f(v)$
2) ចំពោះគ្រប់ $u \in E$ និង គ្រប់ $\alpha \in \mathbb{K}, f(\alpha u) = \alpha f(u)$
គេមាន $E$ លំហវ៉ិចទ័រលើកាយ $\mathbb{K}$ ។
គេហៅ **ទម្រង់លីនេអ៊ែរលើ** $E$ គឺអនុវត្តលីនេអ៊ែរ $f : E \longrightarrow \mathbb{K}$ ។

## ២.១. ផលគុណស្កាលែរ និង ណមន្ទំ

និយមន័យ1,1
គេមាន $E$ លំហវ៉ិចទ័រមួយលើកាយ $\mathbb{R}$ ។
គេហៅ **ផលគុណស្កាលែរ**លើ $E$ គ្រប់អនុវត្ត $\langle .,. \rangle : E \times E \longrightarrow \mathbb{R}$

$$(x,y) \longmapsto \langle x,y \rangle$$

ដែលមានទម្រង់៖
1) បីលីនេអ៊ែរ៖ ចំពោះគ្រប់ $x \in E$ អនុវត្ត $\langle x,. \rangle$ និង $\langle .,x \rangle$ ជាអនុវត្តលីនេអ៊ែរ
2) ស៊ីមេទ្រិក៖ ចំពោះគ្រប់ $(x,y) \in E^2, \langle x,y \rangle = \langle y,x \rangle$
3) កំណត់-វិជ្ជមាន៖ ចំពោះគ្រប់ $x \in E,\ \langle x,x \rangle \geq 0$ និង ($\langle x,x \rangle = 0$ គេបាន $x = 0_E$)

កាលណាលំហវ៉ិចទ័រ $E$ ប្រដាប់ដោយផលគុណស្កាលែរ $\langle .,. \rangle$ មួយ គេថា គូ $(E, \langle .,. \rangle)$ ជា **លំហប្រេអ៊ីលប៊ែរយ៉ាំងចំនួនពិត** ។ លើសពីនេះ បើលំហវ៉ិចទ័រ $E$ មានវិមាត្រកំណត់ គេហៅថា **លំហអឺគ្លីត**។

ឧទាហរណ៍1,1 គេមានលំហវ៉ិចទ័រចំនួនពិត $\mathbb{R}^3$ និង អនុវត្ត $\varphi : \mathbb{R}^3 \times \mathbb{R}^3 \longrightarrow \mathbb{R}$ ដែលកំណត់ដោយ៖

$$\varphi(x,y) = x_1y_1 + 2x_2y_2 + 3x_3y_3 + x_1y_2 + x_2y_1$$

បង្ហាញថា អនុវត្ត $\varphi$ ជាផលគុណស្កាលែរមួយលើ $\mathbb{R}^3$ ។
ចម្លើយ
បង្ហាញថា អនុវត្ត $\varphi$ ជាផលគុណស្កាលែរមួយលើ $\mathbb{R}^3$ គឺបង្ហាញថា $\varphi$ មានទម្រង់
បីលីនេអ៊ែរ-ស៊ីមេទ្រិក កំណត់វិជ្ជមាន លើ $\mathbb{R}^3$។
ជាទូទៅ គេចាប់ផ្តើមបង្ហាញនូវទម្រង់ស៊ីមេទ្រិក បន្ទាប់មកទម្រង់បីលីនេអ៊ែរ និងបញ្ចប់ដោយទម្រង់កំណត់-វិជ្ជមាន។ ជម្រើសនៃការបង្ហាញនូវទម្រង់ស៊ីមេទ្រិកជាមុន គឺសម្រួលដល់ការបង្ហាញនូវទម្រង់

ប៊ីលីនេអ៊ែរ ដោយគ្រាន់តែបង្ហាញថាអនុវត្តដោយផ្នែកមួយជាអនុវត្តលីនេអ៊ែរ
ឧទាហរណ៍ $\varphi_x$ ៖ ចំពោះអនុវត្ត $\varphi_x$ គឺគេកំណត់អថេរ $x$ នៅនឹង និង គេសង្កេតមើលទៅលើភាពលីនេអ៊ែរជាមួយនឹងអថេរ $y$។

គេមាន $\varphi(x,y) = x_1y_1 + 2x_2y_2 + 3x_3y_3 + x_1y_2 + x_2y_1$

ដែល $x = (x_1, x_2, x_3) \in \mathbb{R}^3$ និង $y = (y_1, y_2, y_3) \in \mathbb{R}^3$ ។

1) អនុវត្ត $\varphi$ មានទម្រង់ស៊ីមេទ្រិកលើ $\mathbb{R}^3$ គឺជាក់ស្តែង ពីព្រោះថា ផលគុណនិងផលបូកនៃពីរចំនួនពិតមានលក្ខណៈត្រលប់។

$$\varphi(x,y) = x_1y_1 + 2x_2y_2 + 3x_3y_3 + x_1y_2 + x_2y_1$$
$$\varphi(x,y) = y_1x_1 + 2y_2x_2 + 3y_3x_3 + y_2x_1 + y_1x_2$$
$$\varphi(x,y) = y_1x_1 + 2y_2x_2 + 3y_3x_3 + y_1x_2 + y_2x_1$$
$$\varphi(x,y) = \varphi(y,x)$$

2) បង្ហាញថាអនុវត្ត $\varphi$ មានទម្រង់ប៊ីលីនេអ៊ែរលើ $\mathbb{R}^3$ គ្រាន់តែបង្ហាញថាអនុវត្តដោយផ្នែកជាឧទាហរណ៍ $\varphi_x$ គឺជាអនុវត្តលីនេអ៊ែរ (មានន័យថា ចំពោះអនុវត្ត $\varphi_x$ គេកំណត់អថេរ $x$ នៅនឹង និង គេសង្កេតមើលទៅលើភាពលីនេអ៊ែរជាមួយនឹងអថេរ $y$)។

តាងអនុវត្តដោយផ្នែក $\varphi_x$ ៖ $\mathbb{R}^3 \longrightarrow \mathbb{R}$

$$y \longmapsto \varphi_x(y) = \varphi(x,y)$$

គេនឹងបង្ហាញថាអនុវត្ត $\varphi_x$ គឺជាអនុវត្តលីនេអ៊ែរ គឺគេនឹងបង្ហាញថា៖

ចំពោះ $y, z \in \mathbb{R}^3$ និង $\alpha \in \mathbb{R}$ គេបាន $\varphi_x(\alpha y + z) = \alpha\varphi_x(y) + \varphi_x(z)$

ចំពោះ $y, z \in \mathbb{R}^3$ និង $\alpha \in \mathbb{R}$ គេមាន $\varphi_x(\alpha y + z) = \varphi(x, \alpha y + z)$

$$\varphi_x(\alpha y + z) = x_1(\alpha y_1 + z_1) + 2x_2(\alpha y_2 + z_2) + 3x_3(\alpha y_3 + z_3) + x_1(\alpha y_2 + z_2) + x_2(\alpha y_1 + z_1)$$
$$\varphi_x(\alpha y + z) = \alpha(x_1y_1 + 2x_2y_2 + 3x_3y_3 + x_1y_2 + x_2y_1) + (x_1z_1 + 2x_2z_2 + 3x_3z + x_1z_2 + x_2z_1)$$
$$\varphi_x(\alpha y + z) = \alpha\varphi(x,y) + \varphi(x,z)$$
$$\varphi_x(\alpha y + z) = \alpha\varphi_x(y) + \varphi_x(z)$$

3) បង្ហាញថាអនុវត្ត $\varphi$ មានទម្រង់កំណត់-វិជ្ជមានលើ $\mathbb{R}^3$

ចំពោះ $x \in \mathbb{R}^3$ គេមាន $\varphi(x,x) = x_1^2 + 2x_2^2 + 3x_3^2 + x_1x_2 + x_2x_1$

$$\varphi(x,x) = x_1^2 + 2x_2^2 + 3x_3^2 + 2x_1x_2$$
$$\varphi(x,x) = (x_1^2 + 2x_1x_2 + x_2^2) + x_2^2 + 3x_3^2$$
$$\varphi(x,x) = (x_1 + x_2)^2 + x_2^2 + 3x_3^2$$

គេបាន $\varphi(x,x) \geq 0$

និង បើ $\varphi(x,x) = 0$ នោះ $(x_1 + x_2)^2 + x_2^2 + 3x_3^2 = 0$

$$\begin{cases} x_1 + x_2 = 0 \\ x_2 = 0 \\ x_3 = 0 \end{cases}$$

គេបាន $x_1 = x_2 = x_3 = 0$

ដូច្នេះអនុវត្ត $\varphi$ មានទម្រង់កំណត់-វិជ្ជមានលើ $\mathbb{R}^3$

ឧទាហរណ៍1.2 ក្នុង $\mathbb{R}^n$ អនុវត្ត $\langle .,. \rangle : \mathbb{R}^n \times \mathbb{R}^n \longrightarrow \mathbb{R}$

$$(x, y) \longmapsto \sum_{i=1}^{n} x_i y_i$$

គឺជាផលគុណស្កាលែរមួយលើ $\mathbb{R}^n$ (ហៅថា ផលគុណស្កាលែរកាណូនិកលើ $\mathbb{R}^n$) ។

ឧទាហរណ៍1.3 ក្នុង $C^0([a,b],\mathbb{R})$ លំហវ៉ិចទ័រចំនួនពិតនៃអនុវត្តជាប់លើចន្លោះ $[a,b]$ ដែលឱ្យតម្លៃក្នុង $\mathbb{R}$ អនុវត្ត $\langle .,. \rangle : C^0([a,b],\mathbb{R}) \times C^0([a,b],\mathbb{R}) \longrightarrow \mathbb{R}$

$$(f, g) \longmapsto \int_a^b f(x)g(x)dx$$

គឺជាផលគុណស្កាលែរមួយលើ $C^0([a,b],\mathbb{R})$ ។

ឧទាហរណ៍1,4 ក្នុង $M_n(\mathbb{R})$ អនុវត្ត $\langle .,. \rangle : M_n(\mathbb{R}) \times M_n(\mathbb{R}) \longrightarrow \mathbb{R}$

$$(A, B) \longmapsto \mathrm{Tr}(A^T B)$$

គឺជាផលគុណស្កាលែរមួយលើ $M_n(\mathbb{R})$ (ហៅថា ផលគុណស្កាលែរកាណូនិកលើ $M_n(\mathbb{R})$) ។

**និយមន័យ**2.2 [**ណមផ្ដុំនឹងផលគុណស្កាលែរ**]

គេមានលំហអឺក្លីត $(E, \langle .,. \rangle)$ ។

គេហៅ**ណមផ្ដុំ**នឹងផលគុណស្កាលែរគឺ អនុវត្ត $N : E \longrightarrow \mathbb{R}$

$$x \longmapsto \sqrt{\langle x, x \rangle}$$

គេតាងចំនួនពិត $N(x)$ ជាញឹកញាប់ដោយ $\|x\|$ (អានថា៖ ណមនៃវ៉ិចទ័រ $x$ នៃ $E$ )។

ដូច្នេះ គេបាន $\|x\|^2 = \langle x, x \rangle$ ។

ឧទាហរណ៍1.5 ក្នុងលំហវ៉ិចទ័រចំនួនពិត $\mathbb{R}^n$ ប្រដាប់ដោយផលគុណស្កាលែរកាណូនិករបស់វា ចំពោះ $x = (x_1, \dots, x_n)$ គេបាន $\|x\| = \sqrt{x_1^2 + \dots + x_n^2}$ ។

**ទ្រឹស្ដីបទ**2.3 [វិសមភាព Cauchy-Schwarz]

គេមានលំហអឺក្លីត $(E, \langle .,. \rangle)$ និង $\|.\|$ ណមផ្ដុំនឹងផលគុណស្កាលែរ $\langle .,. \rangle$ ។

នោះចំពោះគ្រប់ $(x, y) \in E^2, |\langle x, y \rangle| \le \|x\| \times \|y\|$ ។

លើសពីនេះ វិសមភាពនេះជា*សមភាព*លុះត្រាតែ $(x, y)$ ជាគ្រួសារអាស្រ័យលីនេអ៊ែរមួយនៃ $E$ ។

ឧទាហរណ៍1,6 វិសមភាព Cauchy-Schwarz លើ $\mathbb{R}^n$ ៖

ចំពោះ $x = (x_1, \dots, x_n) \in \mathbb{R}^n$ $y = (y_1, \dots, y_n) \in \mathbb{R}^n$ គេបាន៖

$|\sum_{i=1}^{n} x_i y_i| \le \sqrt{\sum_{i=1}^{n} x_i^2} \times \sqrt{\sum_{i=1}^{n} y_i^2}$ និង $(\sum_{i=1}^{n} x_i y_i)^2 \le \left(\sum_{i=1}^{n} x_i^2\right) \times \left(\sum_{i=1}^{n} y_i^2\right)$

ឧទាហរណ៍1,7 វិសមភាព Cauchy-Schwarz លើ $C^0([a,b],\mathbb{R})$ ៖

ចំពោះគ្រប់ $(f,g)\in\left(C^0([a,b],\mathbb{R})\right)^2, \left|\int_a^b fg\right| \leq \sqrt{\int_a^b f^2}\times\sqrt{\int_a^b g^2}$

និង $\left(\int_a^b fg\right)^2 \leq \left(\int_a^b f^2\right)\times\left(\int_a^b g^2\right)$

**លក្ខណៈ**2.4

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ និង $\|.\|$ ណមផ្ទុំនឹងផលគុណស្កាលែរ $\langle .,.\rangle$ ។

គេបានលក្ខណៈដូចខាងក្រោម៖

1) ចំពោះគ្រប់ $x\in E$ និង គ្រប់ $\lambda\in\mathbb{R}, \|\lambda x\| = |\lambda|\times\|x\|$

2) ចំពោះគ្រប់ $x\in E, \|x\|\geq 0$

3) ចំពោះគ្រប់ $x\in E, \|x\| = 0 \Rightarrow x = 0_E$

4) ចំពោះគ្រប់ $(x,y)\in E^2, \|x+y\|\leq\|x\|+\|y\|$

5) ចំពោះគ្រប់ $(x,y)\in E^2,\ \|x+y\| = \|x\|+\|y\|$ លុះត្រាតែ $(x,y)$ ជាគ្រួសារអាស្រ័យលីនេអ៊ែរមួយនៃ $E$ ។

**លក្ខណៈ**2.5

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ និង $\|.\|$ ណមផ្ទុំនឹងផលគុណស្កាលែរ $\langle .,.\rangle$ ។

គេបានលក្ខណៈដូចខាងក្រោម៖

1) ចំពោះគ្រប់ $(x,y)\in E^2, \|x+y\|^2 = \|x\|^2+2\langle x,y\rangle+\|y\|^2$

2) ចំពោះគ្រប់ $(x,y)\in E^2, \|x-y\|^2 = \|x\|^2-2\langle x,y\rangle+\|y\|^2$

3) ចំពោះគ្រប់ $(x,y)\in E^2, \langle x-y,x+y\rangle = \|x\|^2-\|y\|^2$

4) ចំពោះគ្រប់ $(x,y)\in E^2, \|x+y\|^2+\|x-y\|^2 = 2(\|x\|^2+\|y\|^2)$

5) ចំពោះគ្រប់ $(x,y)\in E^2, \langle x,y\rangle = \frac{1}{2}(\|x+y\|^2-\|x\|^2-\|y\|^2)$

6) ចំពោះគ្រប់ $(x,y)\in E^2, \langle x,y\rangle = \frac{1}{4}(\|x+y\|^2-\|x-y\|^2)$

ជាបន្តនេះ យើងនឹងសិក្សាក្នុងលំហអឺគ្លីត $(E,\langle .,.\rangle)$ ។

## ២.២. ភាពអរតូកូណាល់ និង គោលអរតូណរម៉ាល់

**<u>និយមន័យ</u>**2.6

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ ។

1) គេថាពីរវ៉ិចទ័រ $x$ និង $y$ នៃ $E$ **អរតូកូណាល់**គ្នា( ដែលតាងដោយ $x\perp y$ )
   បើ $\langle x,y\rangle = 0$ ។

2) គេមាន $\mathcal{F} = (x_i)_{i\in[\![1,p]\!]}$ ជាគ្រួសារនៃវ៉ិចទ័រនៃ $E$ ។ គេថា $\mathcal{F}$ ជា**គ្រួសារអរតូកូណាល់**
   បើគ្រប់គូ $(i,j)\in[\![1,p]\!]^2$ ដែល $i\neq j$ វ៉ិចទ័រ $x_i\perp x_j$ ។

ទ្រឹស្តីបទ2.7 [**ទ្រឹស្តីបទពីតាគ័រ**]

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ និង $\|.\|$ ណមផ្ទុំនឹងផលគុណស្កាលែរ $\langle .,.\rangle$ ។

គេមាន $\mathcal{F}=(x_i)_{i\in[\![1,p]\!]}$ ជាគ្រួសារអរតូកូណាល់កំណត់មួយនៃ $E$ នោះគេបាន៖ $\left\|\sum_{i=1}^{p} x_i\right\|^2=\sum_{i=1}^{p}\|x_i\|^2$ ។

ប្រយ័ត្ន៖ ប្រាសមកវិញគឺមិនពិត (លើកលែងតែករណី $p=2$)។ ជាឧទាហរណ៍ ក្នុង $\mathbb{R}^3$ យក $x_1=(1,0,0), x_2=(1,1,0), x_3=(-1,1,0)$ ។

លក្ខណៈ2.7

គ្រប់គ្រួសារអរតូកូណាល់នៃលំហអឺគ្លីតដែលមិនផ្ទុកវ៉ិចទ័រសូន្យជាគ្រួសារមិនអាស្រ័យលីនេអ៊ែរ។

និយមន័យ2.8

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ និង $F$ ជាលំហវ៉ិចទ័ររងនៃ $E$ ។

គេហៅ**អរតូកូណាល់នៃ** $F$ (ដែលតាងដោយ $F^\perp$) កំណត់ដោយ៖

$$F^\perp=\{x\in E \mid \text{គ្រប់ } y\in F, \langle x,y\rangle=0\} \text{ ។}$$

កំណត់សម្គាល់៖ 1) $\{0\}^\perp=E$ និង 2) $E^\perp=\{0\}$ ។

លក្ខណៈ2.9

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ ។ បើ $F$ និង $G$ ជាលំហវ៉ិចទ័ររងនៃ $E$ នោះគេបាន៖

1) $E=F\oplus F^\perp$ (មានន័យថា៖ $E=F+F^\perp$ និង $F\cap F^\perp=\{0\}$)

($F$ និង $F^\perp$ គឺជា**លំហវ៉ិចទ័ររងបន្ថែមគ្នា**ក្នុង $E$)

2) $F=(F^\perp)^\perp$

3) $(F+G)^\perp=F^\perp\cap G^\perp$ និង $(F\cap G)^\perp=F^\perp+G^\perp$

និយមន័យ2.10

គេមានលំហអឺគ្លីត $(E,\langle .,.\rangle)$ ។

គោល $\mathcal{B}=(e_1,e_2,\dots,e_p)$ មួយជា**គោលអរតូកូណាល់** បើ $\langle e_i,e_j\rangle=0$ ចំពោះគ្រប់ $(i,j)\in[\![1,p]\!]^2$ ដែល $i\neq j$ ។

គោល $\mathcal{B}$ ជា**គោលអរតូណរមេ** បើលើសពីនេះ វ៉ិចទ័រនីមួយៗមានណមស្មើនឹង 1 គឺមានន័យថា៖ $\langle e_i,e_j\rangle=\delta_{ij}$ ដែល $\delta_{ij}$ ជានិម្មិតសញ្ញាក្រូនិកគ័រ (*Kronecker*) កំណត់ដោយ

$$\delta_{ij}=\begin{cases}1 & \text{បើ } i=j\\ 0 & \text{បើ } i\neq j\end{cases} \text{ ។}$$

កំណត់សម្គាល់៖ បើ $\{\varepsilon_i\}$ ជាគោលអរតូកូណាល់មួយ នោះវ៉ិចទ័រ $e_i = \frac{\varepsilon_i}{\|\varepsilon_i\|}$ កំណត់នូវគោលអរតូណរមេមួយ។

| |
|---|
| ទ្រឹស្តីបទ2.11 |
| ក្នុងលំហអឺគ្លីត មានជានិច្ចជាកាលនូវគោលអរតូណរមេ។ |

គេមាន $\mathcal{B} = (e_1, e_2, \dots, e_p)$ ជាគោលអរតូណរមេមួយ និង $x = \sum_{i=1}^{p} x_i e_i \, , y = \sum_{j=1}^{p} y_j e_j$ ជាពីរវ៉ិចទ័រនៃ $E$ ។

គេបាន $\langle x, y\rangle = \langle \sum_{i=1}^{p} x_i e_i \, , \sum_{j=1}^{p} y_j e_j\rangle = \sum_{i,j=1}^{p} x_i y_j \langle e_i, e_j\rangle = \sum_{i,j=1}^{p} x_i y_j \delta_{ij}$

$$\langle x, y\rangle = x_1 y_1 + \cdots + x_p y_p$$

| |
|---|
| លក្ខណៈ2.12 [**វិធាន Gram-Schmidt**] |
| គេមាន $\{v_1, v_2, \dots, v_p\}$ ជាគ្រួសារមួយមិនអាស្រ័យលីនេអ៊ែរនៃលំហអឺគ្លីត $E$ និង $F$ ជាលំហរងបង្ក។ ដូច្នេះ គេអាចសង់ចេញពីគ្រួសារ $\{v_1, v_2, \dots, v_p\}$ នូវគោលអរតូណរមេមួយនៃ $F$ ។ |
| ជាពិសេស គេអាចផ្គុំនឹងគ្រប់គោលនៃ $E$ នូវគោលអរតូណរមេនៃ $E$ ។ |

វិធាន Gram-Schmidt គឺសង់ជាបឋមតាមកំនើននូវគោលអរតូកូណាល់ $(\varepsilon_1, \varepsilon_2, \dots, \varepsilon_p)$ នៃ $F$ និងជាបន្ទាប់នូវគោលអរតូណរមេ $(e_1, e_2, \dots, e_p)$ នៃ $F$ ដែល $e_i = \frac{\varepsilon_i}{\|\varepsilon_i\|}$ ។

ដូចនេះ ចំពោះវិធាននេះ គេយក $\varepsilon_1 = v_1$

$\varepsilon_2 = v_2 + \lambda\varepsilon_1$ ជាមួយនឹងស្កាលែ $\lambda$ ដែល $\varepsilon_2 \perp \varepsilon_1$ ។

ក្រោមលក្ខខ័ណ្ឌនេះ គេបាន៖ $0 = \langle \varepsilon_2, \varepsilon_1\rangle = \langle v_2 + \lambda\varepsilon_1, \varepsilon_1\rangle = \langle v_2, \varepsilon_1\rangle + \lambda\langle \varepsilon_1, \varepsilon_1\rangle$

$$0 = \langle v_2, \varepsilon_1\rangle + \lambda\|\varepsilon_1\|^2$$

ដោយ $\varepsilon_1 \neq 0$ គេបាន $\lambda = -\frac{\langle v_2, \varepsilon_1\rangle}{\|\varepsilon_1\|^2}$ ។

ពេលសង់បាន $\varepsilon_2$ រួចហើយ គេសង់ $\varepsilon_3$ ដោយយក $\varepsilon_3 = v_3 + \lambda\varepsilon_1 + \mu\varepsilon_2$ ជាមួយនឹងស្កាលែរ $\lambda$ និង $\mu$ ដែល $\varepsilon_3 \perp \varepsilon_1$ និង $\varepsilon_3 \perp \varepsilon_2$ ។

គេបាន៖ $0 = \langle v_3 + \lambda\varepsilon_1 + \mu\varepsilon_2, \varepsilon_1\rangle = \langle v_3, \varepsilon_1\rangle + \lambda\|\varepsilon_1\|^2$ ពីព្រោះថា $\langle \varepsilon_2, \varepsilon_1\rangle = 0$

និង $0 = \langle v_3 + \lambda\varepsilon_1 + \mu\varepsilon_2, \varepsilon_2\rangle = \langle v_3, \varepsilon_2\rangle + \mu\|\varepsilon_2\|^2$ ពីព្រោះថា $\langle \varepsilon_1, \varepsilon_2\rangle = 0$

នាំឱ្យ $\lambda = -\frac{\langle v_3, \varepsilon_1\rangle}{\|\varepsilon_1\|^2}$ និង $\mu = -\frac{\langle v_3, \varepsilon_2\rangle}{\|\varepsilon_2\|^2}$ ។

ពេលនេះ គេឃើញច្បាស់នូវវិធានតាមកំនើន។

គេឧបមាថាបានសង់ $\varepsilon_1, \varepsilon_2, \dots, \varepsilon_{p-1}$ រួចហើយ

គេយក $\varepsilon_p = v_p + \lambda_1\varepsilon_1 + \lambda_2\varepsilon_2 + \cdots + \lambda_{p-1}\varepsilon_{p-1}$ ជាមួយនឹងស្កាលែរ $\lambda_i$ ដែល $\varepsilon_p \perp \varepsilon_i$ ចំពោះ $i \in [\![1, p-1]\!]$ ។

ក្រោមលក្ខខ័ណ្ឌនេះ គេរកបាន $\lambda_i = -\frac{\langle v_p, \varepsilon_i\rangle}{\|\varepsilon_i\|^2}$ ។

លំនាំនៃការសង់ខាងលើនេះ គឺបញ្ជាក់ច្បាស់ថា $\{\varepsilon_1, \varepsilon_2, \dots, \varepsilon_p\}$ ជាគ្រួសារអរតូកូណាល់មួយនៃ $F$ និងគេបាន $\mathrm{Vect}(v_1, v_2, \dots, v_p) = \mathrm{Vect}(\varepsilon_1, \varepsilon_2, \dots, \varepsilon_p)$ ។

ឧទាហរណ៍1,8 ក្នុង $\mathbb{R}^3$ គេមានបីវ៉ិចទ័រ $v_1 = \begin{pmatrix} 1 \\ 0 \\ -1 \end{pmatrix}, v_2 = \begin{pmatrix} 1 \\ -1 \\ -1 \end{pmatrix}, v_3 = \begin{pmatrix} 1 \\ -1 \\ 0 \end{pmatrix}$ ។

1) បង្ហាញថា $\{v_1, v_2, v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $\mathbb{R}^3$ ។

2) កំណត់រកតាមវិធាន Gram-Schmidt នូវគោលអរតូណរមេមួយនៃ $\mathbb{R}^3$ ។

ចម្លើយ

1) បង្ហាញថា $\{v_1, v_2, v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $\mathbb{R}^3$

បើ $\sum_{i=1}^{3} \lambda_i v_i = 0$ ដែលចំពោះ $i \in [\![1,3]\!], \lambda_i \in \mathbb{R}$

គេបាន $\lambda_1 \begin{pmatrix} 1 \\ 0 \\ -1 \end{pmatrix} + \lambda_2 \begin{pmatrix} 1 \\ -1 \\ -1 \end{pmatrix} + \lambda_3 \begin{pmatrix} 1 \\ -1 \\ 0 \end{pmatrix} = 0$

$$\begin{cases} \lambda_1 + \lambda_2 + \lambda_3 = 0 & L_1 \\ -\lambda_2 - \lambda_3 = 0 & L_2 \\ -\lambda_1 - \lambda_2 = 0 & L_3 \end{cases}$$

$$\begin{cases} \lambda_1 + \lambda_2 = 0 & L_1 \leftrightarrow -L_3 \\ \lambda_2 + \lambda_3 = 0 & L_2 \longleftarrow -L_2 \\ \lambda_1 + \lambda_2 + \lambda_3 = 0 & \end{cases}$$

$$\begin{cases} \lambda_1 + \lambda_2 = 0 & L_1 \\ \lambda_2 + \lambda_3 = 0 & L_2 \\ \lambda_3 = 0 & L_3 \longleftarrow L_3 - L_1 \end{cases}$$

តាម $L_2$ គេបាន $\lambda_2 = 0$ និង តាម $L_1$ គេបាន $\lambda_1 = 0$

នាំឱ្យ $\lambda_1 = \lambda_2 = \lambda_3 = 0$

ដូច្នេះ $\{v_1, v_2, v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $\mathbb{R}^3$

2) កំណត់រកគោលអរតូណរមេមួយនៃ $\mathbb{R}^3$

តាម 1) គ្រួសារ $\{v_1, v_2, v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $\mathbb{R}^3$

តាមវិធាន Gram-Schmidt គេនឹងសង់តាមកំនើនចេញពីគ្រួសារ $\{v_1, v_2, v_3\}$ នូវគោលអរតូកូណាល់ $(\varepsilon_1, \varepsilon_2, \varepsilon_3)$ នៃ $\mathbb{R}^3$ និងជាបន្ទាប់នូវគោលអរតូណរមេ $(e_1, e_2, e_3)$ នៃ $\mathbb{R}^3$ ដែល $e_i = \frac{\varepsilon_i}{\|\varepsilon_i\|}$ ។

គេយក $\varepsilon_1 = v_1$

$\varepsilon_2 = v_2 + \lambda\varepsilon_1$ ជាមួយនឹងស្កាលែរ $\lambda \in \mathbb{R}$ ដែល $\varepsilon_2 \perp \varepsilon_1$

ក្រោមលក្ខខណ្ឌនេះ គេបាន $\lambda = -\frac{\langle v_2,\varepsilon_1\rangle}{\|\varepsilon_1\|^2} = -\frac{1\times1+(-1)\times0+(-1)\times(-1)}{1^2+0^2+(-1)^2} = -\frac{2}{2} = -1$

គេបាន $\varepsilon_2 = \begin{pmatrix}1\\-1\\-1\end{pmatrix} + (-1)\begin{pmatrix}1\\0\\-1\end{pmatrix} = \begin{pmatrix}1-1\\-1-0\\-1+1\end{pmatrix} = \begin{pmatrix}0\\-1\\0\end{pmatrix}$

គេយក $\varepsilon_3 = v_3 + \alpha\varepsilon_1 + \beta\varepsilon_2$ ជាមួយនឹងស្កាលែរ $\alpha,\beta \in \mathbb{R}$ ដែល $\varepsilon_3 \perp \varepsilon_1$ និង $\varepsilon_3 \perp \varepsilon_2$

ក្រោមលក្ខខណ្ឌនេះ គេបាន $\alpha = -\frac{\langle v_3,\varepsilon_1\rangle}{\|\varepsilon_1\|^2} = -\frac{1\times1+(-1)\times0+0\times(-1)}{1^2+0^2+(-1)^2} = -\frac{1}{2}$

និង $\beta = -\frac{\langle v_3,\varepsilon_2\rangle}{\|\varepsilon_2\|^2} = -\frac{1\times0+(-1)\times(-1)+0\times0}{0^2+(-1)^2+0^2} = -1$

គេបាន $\varepsilon_3 = \begin{pmatrix}1\\-1\\0\end{pmatrix} + \left(-\frac{1}{2}\right)\begin{pmatrix}1\\0\\-1\end{pmatrix} + (-1)\begin{pmatrix}0\\-1\\0\end{pmatrix}$

$$\varepsilon_3 = \left(-\frac{1}{2}\right)\begin{pmatrix}-2+1+0\\2+0-2\\0-1+0\end{pmatrix} = \left(-\frac{1}{2}\right)\begin{pmatrix}-1\\0\\-1\end{pmatrix} = \frac{1}{2}\begin{pmatrix}1\\0\\1\end{pmatrix} = \frac{1}{2}\varepsilon_3'$$

ដែល $\varepsilon_3' = \begin{pmatrix}1\\0\\1\end{pmatrix}$

( $\varepsilon_3$ និង $\varepsilon_3'$ កូលីនេអ៊ែរគ្នា ហើយ $\varepsilon_3 \perp \varepsilon_1$ និង $\varepsilon_3 \perp \varepsilon_2$ ដូចនេះ $\varepsilon_3' \perp \varepsilon_1$ និង $\varepsilon_3' \perp \varepsilon_2$ )

ដូច្នេះ $(\varepsilon_1,\varepsilon_2,\varepsilon_3')$ ជាគោលអរត្តូកូណាល់មួយនៃ $\mathbb{R}^3$ ដែល

$$\varepsilon_1 = \begin{pmatrix}1\\0\\-1\end{pmatrix}, \quad \varepsilon_2 = \begin{pmatrix}0\\-1\\0\end{pmatrix}, \quad \varepsilon_3' = \begin{pmatrix}1\\0\\1\end{pmatrix}$$

គេទាញបាន $(e_1,e_2,e_3)$ ជាគោលអរត្តូណរមេមួយនៃ $\mathbb{R}^3$ ដែល

$$e_1 = \frac{\varepsilon_1}{\|\varepsilon_1\|} = \frac{1}{\sqrt{1^2+0^2+(-1)^2}}\begin{pmatrix}1\\0\\-1\end{pmatrix} = \frac{1}{\sqrt{2}}\begin{pmatrix}1\\0\\-1\end{pmatrix}$$

$$e_2 = \frac{\varepsilon_2}{\|\varepsilon_2\|} = \frac{1}{\sqrt{0^2+(-1)^2+0^2}}\begin{pmatrix}0\\-1\\0\end{pmatrix} = \begin{pmatrix}0\\-1\\0\end{pmatrix}$$

$$e_3 = \frac{\varepsilon_3'}{\|\varepsilon_3'\|} = \frac{1}{\sqrt{1^2+0^2+1^2}}\begin{pmatrix}1\\0\\1\end{pmatrix} = \frac{1}{\sqrt{2}}\begin{pmatrix}1\\0\\1\end{pmatrix}$$

<u>ឧទាហរណ៍1,9</u> កំណត់រកគោលអរត្តូណរមេមួយនៃលំហវ៉ិចទ័ររង $F$ នៃ $\mathbb{R}^4$ ដែលបង្កដោយ

វ៉ិចទ័រ $v_1 = \begin{pmatrix}1\\1\\0\\0\end{pmatrix}, v_2 = \begin{pmatrix}1\\0\\-1\\1\end{pmatrix}, v_3 = \begin{pmatrix}0\\1\\1\\1\end{pmatrix}$ ។

<u>ចម្លើយ</u>

ជាបឋម គេនឹងផ្ទៀងផ្ទាត់ថា $\{v_1,v_2,v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $F$

បើ $\sum_{i=1}^{3}\lambda_i v_i = 0$ ដែលចំពោះ $i \in [\![1,3]\!], \lambda_i \in \mathbb{R}$

គេបាន $\lambda_1\begin{pmatrix}1\\1\\0\\0\end{pmatrix}+\lambda_2\begin{pmatrix}1\\0\\-1\\1\end{pmatrix}+\lambda_3\begin{pmatrix}0\\1\\1\\1\end{pmatrix}=0$

$$\begin{cases}\lambda_1+\lambda_2 = 0 & L_1\\ \lambda_1 + \lambda_3 = 0 & L_2\\ -\lambda_2+\lambda_3 = 0 & L_3\\ \lambda_2+\lambda_3=0 & L_4\end{cases}$$

$$\begin{cases}\lambda_1+\lambda_2 = 0 & L_1\\ \lambda_2 + \lambda_3 = 0 & L_2\leftrightarrow L_4\\ -\lambda_2+\lambda_3 = 0 & L_3\\ \lambda_1+\lambda_3=0 & L_4\end{cases}$$

$$\begin{cases}\lambda_1+\lambda_2 = 0 & L_1\\ \lambda_2 + \lambda_3 = 0 & L_2\\ -\lambda_2+\lambda_3 = 0 & L_3\\ -\lambda_2+\lambda_3=0 & L_4\leftarrow L_4-L_1\end{cases}$$

$$\begin{cases}\lambda_1+\lambda_2 = 0 & L_1\\ \lambda_2 + \lambda_3 = 0 & L_2\\ \lambda_3 = 0 & L_3\leftarrow 1/2\,(L_3+L_2)\end{cases}$$

តាម $L_2$ គេបាន $\lambda_2=0$ និង តាម $L_1$ គេបាន $\lambda_1=0$

នាំឱ្យ $\lambda_1=\lambda_2=\lambda_3=0$

ដូច្នេះ $\{v_1,v_2,v_3\}$ ជាគ្រួសារមិនអាស្រ័យលីនេអ៊ែរនៃ $F$

តាមវិធាន Gram-Schmidt គេនឹងសង់តាមកំនើនចេញពីគ្រួសារ $\{v_1,v_2,v_3\}$ នូវគោលអរតូកូណាល់ $(\varepsilon_1,\varepsilon_2,\varepsilon_3)$ នៃ $F$ និងជាបន្ទាប់នូវគោលអរតូណរមេ $(e_1,e_2,e_3)$ នៃ $F$ ដែល $e_i=\frac{\varepsilon_i}{\|\varepsilon_i\|}$ ។

គេយក $\varepsilon_1=v_1$

$\varepsilon_2=v_2+\lambda\varepsilon_1$ ជាមួយនឹងស្កាលែរ $\lambda\in\mathbb{R}$ ដែល $\varepsilon_2\perp\varepsilon_1$

ក្រោមលក្ខខណ្ឌនេះ គេបាន $\lambda=-\frac{\langle v_2,\varepsilon_1\rangle}{\|\varepsilon_1\|^2}=-\frac{1\times1+0\times1+(-1)\times0+1\times0}{1^2+1^2+0^2+0^2}=-\frac{1}{2}$

គេបាន $\varepsilon_2=\begin{pmatrix}1\\0\\-1\\1\end{pmatrix}+\left(-\frac{1}{2}\right)\begin{pmatrix}1\\1\\0\\0\end{pmatrix}=\begin{pmatrix}1-\frac{1}{2}\\0-\frac{1}{2}\\-1-0\\1-0\end{pmatrix}=\begin{pmatrix}\frac{1}{2}\\-\frac{1}{2}\\-1\\1\end{pmatrix}=\frac{1}{2}\begin{pmatrix}1\\-1\\-2\\2\end{pmatrix}=\frac{1}{2}\varepsilon_2'$

ដែល $\varepsilon_2' = \begin{pmatrix} 1 \\ -1 \\ -2 \\ 2 \end{pmatrix}$

រកតម្លៃផ្ទាលដោយប្រើ $|\lambda I-A|=0 \quad \Rightarrow (\lambda-1)^2(\lambda-4)=0$ គេបាន

$$\lambda_1=\lambda_1=1, \qquad \lambda_2=4$$

ដូច្នេះ $L$ មានតម្លៃផ្ទាល់ $\lambda_1=1$ (ដែលមានពីរកត្តា) និង $\lambda_2=4$ (ដែលមានមួយកត្តា)។
ដើម្បីរកវ៉ិចទ័រផ្ទាល់ដែលផ្គុំដោយតម្លៃផ្ទាល់នីមួយៗយើងដោះស្រាយប្រព័ន្ធអូម៉ូសែន

$$(\lambda I-L)X=0$$

$$\begin{pmatrix}\lambda-2 & -1 & 1\\ -1 & \lambda-2 & 1\\ 1 & 1 & \lambda-2\end{pmatrix}\begin{pmatrix}x_1\\ x_2\\ x_3\end{pmatrix}=\begin{pmatrix}0\\ 0\\ 0\end{pmatrix}$$

- បើ $\lambda=4$ យើងកំណត់យកម៉ាទ្រីសបន្ថែមចំពោះប្រព័ន្ធលីនេអ៊ែរ

$$\begin{pmatrix}2 & 1 & -1\\ 1 & 2 & -3\\ -1 & -1 & 2\end{pmatrix}\begin{pmatrix}x_1\\ x_2\\ x_3\end{pmatrix}=\begin{pmatrix}0\\ 0\\ 0\end{pmatrix}$$

$$\begin{pmatrix}1 & -2 & -1\\ 0 & -3 & -3\\ 0 & -3 & -3\end{pmatrix}\begin{pmatrix}x_1\\ x_2\\ x_3\end{pmatrix}=\begin{pmatrix}0\\ 0\\ 0\end{pmatrix}$$

$$\begin{pmatrix}1 & -2 & -1\\ 0 & 1 & 1\\ 0 & 0 & 0\end{pmatrix}\begin{pmatrix}x_1\\ x_2\\ x_3\end{pmatrix}=\begin{pmatrix}0\\ 0\\ 0\end{pmatrix}$$

$$\begin{pmatrix}1 & 0 & 1\\ 0 & 1 & 1\\ 0 & 0 & 0\end{pmatrix}\begin{pmatrix}x_1\\ x_2\\ x_3\end{pmatrix}=\begin{pmatrix}0\\ 0\\ 0\end{pmatrix}$$

តាង $x_3=t \quad \Rightarrow x_1=x_2=-t$

$$X=\begin{pmatrix}-t\\ -t\\ t\end{pmatrix}=t\begin{pmatrix}-1\\ -1\\ 1\end{pmatrix}$$

វ៉ិចទ័រណាមួយនៃទម្រង់ $t\begin{pmatrix}-1\\-1\\1\end{pmatrix}$ គឺជាវ៉ិចទ័រផ្ទាល់ដែលត្រូវនិងតម្លៃផ្ទាល់ $\lambda = 4$។

ដូច្នេះ $L$ កាត់បន្ទាត់ត្រង់គល់តម្រុយ។

- បើ $\lambda = 1$ម្តងទៀតយើងកំណត់យកម៉ាទ្រីសបន្ថែម និងរកសំណុំចម្លើយ

$$\begin{pmatrix}1 & 1 & -1 & 0\\ 1 & 1 & -1 & 0\\ -1 & -1 & 1 & 0\end{pmatrix} \sim \begin{pmatrix}1 & 1 & -1 & 0\\ 0 & 0 & 0 & 0\\ 0 & 0 & 0 & 0\end{pmatrix}$$

បន្ទាប់មកសំណុំចម្លើយមានប៉ារ៉ាម៉ែត្រពីរគឺ $s$ និង $t$ ព្រោះ $x_3 = s,\ x_2 = t$ , $x_1 = -t + s$

ដូច្នេះ $L$ បានមកពីសំណុំ $X = s\begin{pmatrix}-1\\1\\0\end{pmatrix} + t\begin{pmatrix}1\\0\\1\end{pmatrix}$

សំណុំនេះគឺប្លង់មួយកាត់គល់តម្រុយ។ ដូច្នេះផលគុណពីរតម្លៃផ្ទាល់មានពីរវ៉ិចទ័រផ្ទាល់មិន

អាស្រ័យ $\begin{pmatrix}-1\\1\\0\end{pmatrix}$ និង $\begin{pmatrix}1\\0\\1\end{pmatrix}$ ដែលកំណត់ដោយប្លង់មិនប្រែប្រួល។

## ៤.៣. ស្វ័យគុណនៃម៉ាទ្រីស

ប្លង់នៃតម្លៃផ្ទាល់និងវ៉ិចទ័រផ្ទាល់នៃម៉ាទ្រីស $A$ គឺបានរកឃើញវាគឺជាបញ្ហាសាមញ្ញក្នុងការរកតម្លៃផ្ទាល់និងវ៉ិចទ័រផ្ទាល់នៃស្វ័យគុណវិជ្ជមានណាមួយនៃ $A$។ ឧទាហរណ៍បើ $\lambda$ ជាតម្លៃផ្ទាល់នៃ $A$ ហើយ $x$ ជាវ៉ិចទ័រដែលត្រូវនឹងវានោះ

$$A^2x = A(Ax) = A(\lambda x) = \lambda(Ax) = \lambda(\lambda x) = \lambda^2 x$$

ដូច្នេះ $\lambda^2$ ជាតម្លៃផ្ទាល់នៃ $A^2$ និង $x$ ជាវ៉ិចទ័រផ្ទាល់ដែលត្រូវនិងវា។

ជាទូទៅយើងបានលទ្ធផលដូចខាងក្រោម៖

**ទ្រឹស្តីបទ៥.១.៤** បើ $k$ ជាចំនួនគត់វិជ្ជមាន , $\lambda$ ជាតម្លៃផ្ទាល់នៃម៉ាទ្រីស $A$ និង $x$ ជាវ៉ិចទ័រដែលត្រូវនិងវានោះ $\lambda^k$ និង $x$ ជាវ៉ិចទ័រដែលត្រូវនិងវានោះ។

ឧទាហរណ៍៨៖ ស្វ័យគុណនៃម៉ាទ្រីស រកតម្លៃផ្ទាល់និងវ៉ិចទ័រផ្ទាល់នៃ $A^7$ ។

ក្នុងឧទាហរណ៍៧ យើងបានបង្ហាញថា តម្លៃផ្ទាល់នៃ $A = \begin{bmatrix}0 & 0 & -2\\ 1 & 2 & 1\\ 1 & 0 & 3\end{bmatrix}$

គឺ $\lambda = 2$ និង $\lambda = 1$ បានពីទ្រឹស្តីបទ 5.1.4 ទាំងពីរ $\lambda = 2^7 = 128$ និង $\lambda = 1^7 = 1$ ជាតម្លៃផ្ទាល់នៃ $A^7$ ។ យើងក៏ថែមទាំងបង្ហាញថា $\begin{bmatrix} -1 \\ 1 \\ 0 \end{bmatrix}$ និង $\begin{bmatrix} 0 \\ 1 \\ 0 \end{bmatrix}$ ជាវ៉ិចទ័រផ្ទាល់នៃ $A$ ដែលទាក់ទងទៅនឹងតម្លៃផ្ទាល់ $\lambda = 2$ បានពីទ្រឹស្តីបទ 5.1.4 វាថែមទាំងជាវ៉ិចទ័រផ្ទាល់នៃ $A^7$ ដែលទាក់ទងនឹង $\lambda = 2^7 = 128$ ។ ស្រដៀងគ្នានេះ វ៉ិចទ័រផ្ទាល់ $\begin{bmatrix} -2 \\ 1 \\ 1 \end{bmatrix}$ នៃ $A$ ដែលទាក់ទងទៅនឹងតម្លៃផ្ទាល់ $\lambda = 1$ ក៏ជាវ៉ិចទ័រផ្ទាល់នៃ $A^7$ ដែលទាក់ទងនឹង $\lambda = 1^7 = 1$ ។

**តម្លៃផ្ទាល់ និងភាពច្រាស**

ចំណុចបន្ទាប់នៃទ្រឹស្តីបទបានបង្កើតទំនាក់ទំនងរវាងតម្លៃផ្ទាល់ និងភាពច្រាសនៃម៉ាទ្រីស ។

**ទ្រឹស្តីបទ៥.១.៥** ម៉ាទ្រីសការេ $A$ មួយ គឺច្រាស បើ $\lambda = 0$ មិនមែនជាតម្លៃផ្ទាល់នៃ $A$ ។

## លំហាត់

នៅក្នុងឧទាហរណ៍ 1-2 ទទួលបានដោយការគុណ ដែល $x$ ជាវ៉ិចទ័រផ្ទាល់នៃ $A$ និងស្វែងរកតម្លៃផ្ទាល់ដែលទាក់ទង ។

1. $A = \begin{bmatrix} 4 & 0 & 1 \\ 2 & 3 & 2 \\ 1 & 0 & 4 \end{bmatrix}; \quad X = \begin{bmatrix} 1 \\ 2 \\ 1 \end{bmatrix}$

2. $A = \begin{bmatrix} 2 & -1 & -1 \\ -1 & 2 & -1 \\ -1 & -1 & 2 \end{bmatrix}; \ X = \begin{bmatrix} 1 \\ 1 \\ 1 \end{bmatrix}$

4. រកទម្រង់នៃសមីការសំគាល់នៃម៉ាទ្រីសខាងក្រោម៖

$(a)\quad \begin{bmatrix} 0 & 0 & 2 & 0 \\ 1 & 0 & 1 & 0 \\ 0 & 1 & -2 & 0 \\ 0 & 0 & 0 & 1 \end{bmatrix}$

$(b)\quad \begin{bmatrix} 10 & -9 & 0 & 0 \\ 4 & -2 & 0 & 0 \\ 0 & 0 & -2 & -7 \\ 0 & 0 & 1 & 2 \end{bmatrix}$

5. រកតម្លៃផ្ទាល់នៃម៉ាទ្រីសក្នុងលំហាត់ទី3 ។

$(a)\quad \lambda^4+\lambda^3-3\lambda^2-\lambda+2=0$

$(b)\quad \lambda^4-8\lambda^3+19\lambda^2-24\lambda+48=0$

4. រកគោលនៃលំហផ្ទាល់នៃម៉ាទ្រីសក្នុងលំហាត់ទី3 ។

(a) $\lambda = 1$ : គោល $\begin{bmatrix}2\\3\\1\\0\end{bmatrix}$ , $\begin{bmatrix}0\\0\\0\\1\end{bmatrix}$

$\lambda = 2$ : គោល $\begin{bmatrix}-1\\0\\1\\0\end{bmatrix}$

$\lambda = -1$ : គោល $\begin{bmatrix}-2\\1\\1\\0\end{bmatrix}$

(b) $\lambda = 4$ : គោល $\begin{bmatrix}\frac{3}{2}\\1\\0\\0\end{bmatrix}$

6. ដោយសង្កេតមើល រកតម្លៃផ្ទាល់នៃម៉ាទ្រីសខាងក្រោម៖

$(a).\begin{bmatrix}-1 & 6\\0 & 5\end{bmatrix}$

$(b).\begin{bmatrix}3 & 0 & 0\\-2 & 7 & 0\\4 & 8 & 1\end{bmatrix}$

$(c).\begin{bmatrix}-\frac{1}{3} & 0 & 0 & 0\\0 & -\frac{1}{3} & 0 & 0\\0 & 0 & 1 & 0\\0 & 0 & 0 & \frac{1}{2}\end{bmatrix}$

7. រកតម្លៃផ្ទាល់នៃ $A^9$ :

$$A=\begin{bmatrix} 1 & 3 & 7 & 11 \\ 0 & \frac{1}{2} & 3 & 8 \\ 0 & 0 & 0 & 4 \\ 0 & 0 & 0 & 2 \end{bmatrix}$$

9. តាង $A$ ជាម៉ាទ្រីស $2\times 2$ មួយ និងប្រាប់បន្ទាត់មួយដែលកាត់គល់តម្រុយនៃ $R^2$ ដែលមិនប្រែប្រួលក្រោម $A$ បើ $Ax$ នោះលើបន្ទាត់ដែល $x$ នៅលើ។ រកសមីការបន្ទាត់ទាំងអស់ក្នុង $R^2$ ប្រសិនបើមាន នៅក្នុងម៉ាទ្រីសដែលផ្តល់ឱ្យ ។

$(a).A=\begin{bmatrix} 4 & -1 \\ 2 & 1 \end{bmatrix}$

$(b).A=\begin{bmatrix} 0 & 1 \\ -1 & 0 \end{bmatrix}$

$(c).A=\begin{bmatrix} 2 & 3 \\ 0 & 2 \end{bmatrix}$

10. បង្ហាញថាទម្រង់នៃសមីការម៉ាទ្រីស $2\times 2$ $A$ មួយ អាចសរសេរទៅជា
$\lambda^2 - tr(A)\lambda + \det(A) = 0$ ដែល $tr(A)$ ជា trace នៃ $A$ ។

11. ដោយប្រើប្រាស់លទ្ធផលនៅក្នុងលំហាត់ទី18 ដើម្បីបង្ហាញថាបើ $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$
នោះចម្លើយនៃទម្រង់សមីការនៃ $A$ គឺ

$$\lambda = \frac{1}{2}\left[(a+d) \pm \sqrt{(a-d)^2+4bc}\right]$$

ប្រើប្រាស់លទ្ធផលដើម្បីបង្ហាញថា $A$ មាន

(a) តម្លៃផ្ទាល់ពិតពីរផ្សេងគ្នា បើ $(a-d)^2+4bc>0$

(b) តម្លៃផ្ទាល់ពិតពីរដូចគ្នា បើ $(a-d)^2+4bc=0$

(c) តម្លៃផ្ទាល់កុំផ្លិចផ្សេងគ្នា បើ $(a-d)^2+4bc<0$

## ៤.២. អង្កត់ទ្រូងកម្ម

យើងកត់សម្គាល់ឃើញថា បើម៉ាទ្រីស $B$ វាដូចទៅនឹង $A$ នោះវាក៏ពិតដែរចំពោះ ទ្រីស $A$ វាដូចទៅនឹង $B$ ។ យើងអាចបង្ហាញថា $B$ ដែល $B = Q^{-1}AQ$ ដោយបានពី $Q = P^{-1}$។ ជាករណីដែលយើងជាធម្មតានិយាយថា $A$ និង $B$ ជាម៉ាទ្រីសដូចគ្នា បើមានម៉ាទ្រីសណាមួយដូចទៅនឹងម៉ាទ្រីសមួយទៀត។

ឧទាហរណ៍១ រកម៉ាទ្រីស $P$ ដែលធ្វើអង្កត់ទ្រូងកម្មលើម៉ាទ្រីស $A$

$$A=\begin{bmatrix}0&0&-2\\1&2&1\\1&0&3\end{bmatrix}$$

ដំណោះស្រាយ ក្នុងឧទាហរណ៍ទី៧នៃផ្នែកមុនយើងបានរកឃើញសមីការនៃ $A$ គឺ

$$(\lambda-1)(\lambda-2)^2=0\Rightarrow\lambda=1,\lambda=2$$

ហើយគោលនៃវ៉ិចទ័រផ្ទាល់មាន៖

$$\lambda=2\qquad p_1=\begin{bmatrix}-1\\0\\1\end{bmatrix}, p_2=\begin{bmatrix}0\\1\\0\end{bmatrix}$$

$$\lambda=1\qquad p_3=\begin{bmatrix}-2\\1\\1\end{bmatrix}$$

សរុបមកមានគោលនៃវ៉ិចទ័រផ្ទាល់ចំនួន៣

ដូច្នេះម៉ាទ្រីស $P$ គឺ $P=\begin{bmatrix}-1&0&-2\\0&1&1\\1&0&1\end{bmatrix}$

ផ្ទៀងផ្ទាត់៖ $P^{-1}AP=\begin{bmatrix}1&0&2\\1&1&1\\-1&0&-1\end{bmatrix}\begin{bmatrix}0&0&-2\\1&2&1\\1&0&3\end{bmatrix}\begin{bmatrix}-1&0&-2\\0&1&1\\1&0&1\end{bmatrix}=\begin{bmatrix}2&0&0\\0&2&0\\0&0&1\end{bmatrix}$

ដូច្នេះ $P=\begin{bmatrix}-1&0&-2\\0&1&1\\1&0&1\end{bmatrix}$

ឧទាហរណ៍២ ម៉ាទ្រីស $A$ មិនអាចធ្វើអង្កត់ទ្រូងកម្មបាន

រកម៉ាទ្រីស $P$ ដែលធ្វើអង្កត់ទ្រូងកម្មលើ

$$A=\begin{bmatrix}1&0&0\\1&2&0\\-3&5&2\end{bmatrix}$$

## ដំណោះស្រាយ

សមីការនៃ $A$ គឺ

$$\det(\lambda I - A) = \begin{bmatrix} \lambda-1 & 0 & 0 \\ -1 & \lambda-2 & 0 \\ 3 & -5 & \lambda-2 \end{bmatrix} = (\lambda-1)(\lambda-2)^2$$

សមីការអាចសរសេរ $(\lambda-1)(\lambda-2)^2 = 0 \Rightarrow \lambda = 1, \lambda - 2$

នោះតម្លៃផ្ទាល់នៃ $A$ គឺ $\lambda = 1, \lambda - 2$ ។ យើងនឹងបង្ហាញអ្នកនូវមូលដ្ឋានគោលវ៉ិចទ័រផ្ទាល់ខាងក្រោម

$$\lambda = 1 \qquad p_1 = \begin{bmatrix} \frac{1}{8} \\ -\frac{1}{8} \\ 1 \end{bmatrix}$$

$$\lambda = 2 \qquad p_2 = \begin{bmatrix} 0 \\ 0 \\ 1 \end{bmatrix}$$

ដោយ $A$ ជាម៉ាទ្រីសលំដាប់ $3\times 3$ តែមូលដ្ឋានគោលវ៉ិចទ័រផ្ទាល់នៃ $A$ មានតែ២ នោះ $A$ មិនអាចធ្វើអង្កត់ទ្រូងកម្មបានទេ។

| |
|---|
| ទ្រឹស្តីបទ ៥.២.២ ប្រសិនបើ $(v_1, v_2, \ldots, v_k)$ គឺជាវ៉ិចទ័រផ្ទាល់នៃម៉ាទ្រីស $A$ មួយដែលត្រូវគ្នាជាមួយតម្លៃផ្ទាល់ផ្សេងគ្នា គេថា $(v_1, v_2, \ldots, v_k)$ មិនអាស្រ័យលីនេអ៊ែរ។ |

| |
|---|
| ទ្រឹស្តីបទ ៥.២.៣ បើ $A$ ជាម៉ាទ្រីសមានលំដាប់ $n\times n$ ហើយមាន $n$ តម្លៃផ្ទាល់ផ្សេងគ្នានោះម៉ាទ្រីស $A$ អាចធ្វើអង្កត់ទ្រូងកម្មបាន។ |

ឧទាហរណ៍៣ ប្រើប្រាស់ទ្រឹស្តីបទ ៥.២.៣

យើងបានឃើញក្នុងឧទាហរណ៍ទី៣នៃផ្នែកមុន

$$A = \begin{bmatrix} 0 & 1 & 0 \\ 0 & 0 & 1 \\ 4 & -17 & 8 \end{bmatrix}$$

ម៉ាទ្រីស $A$ មានតម្លៃផ្ទាល់ផ្សេងគ្នាគឺ $\lambda_1 = 4, \lambda_2 = 2+\sqrt{3}$ និង $\lambda_3 = 2-\sqrt{3}$ ដូច្នេះ $A$ អាចធ្វើអង្កត់ទ្រូងកម្មបាននិង

$$P^{-1}AP = \begin{bmatrix} 4 & 0 & 0 \\ 0 & 2+\sqrt{3} & 0 \\ 0 & 0 & 2-\sqrt{3} \end{bmatrix}$$

សម្រាប់ការរកម៉ាទ្រីសឆ្លាស់នៃ $P$ ប្រសិនបើយើងត្រូវការអាចប្រើ $P$ មករកនៅក្នុងឧទាហរណ៍១នៃផ្នែកនេះ។

ឧទាហរណ៍៤ អង្កត់ទ្រូងកម្មនៃម៉ាទ្រីសត្រីកោណ

ចំពោះតម្លៃផ្ទាល់នៃម៉ាទ្រីសត្រីកោណដែលជាធាតុអង្កត់ទ្រូងនៃម៉ាទ្រីសត្រីកោណ។ គេថាម៉ាទ្រីសត្រីកោណដែលមានធាតុខុសគ្នានៅលើអង្កត់ទ្រូងគឺអាចធ្វើអង្កត់ទ្រូងកម្មបាន។

ឧទាហរណ៍ គេមានម៉ាទ្រីស $A$

$$A=\begin{bmatrix} -1 & 2 & 4 & 0 \\ 0 & 3 & 1 & 7 \\ 0 & 0 & 5 & 8 \\ 0 & 0 & 0 & -2 \end{bmatrix}$$

$A$ ជាម៉ាទ្រីសដែលអាចធ្វើអង្កត់ទ្រូងកម្មបានជាមួយនឹងតម្លៃផ្ទាល់

$$\lambda_1=-1, \lambda_2=3, \lambda_3=5, \lambda_4=-2$$

## ៤.២.១.ភាពសមមូល

ម៉ាទ្រីសស្រដៀងគ្នាមានលក្ខណៈដូចគ្នាជាច្រើន។ ឧទាហរណ៍ បើ $B=P^{-1}AP$ នោះវាមានន័យថា $A$ និង $B$ មានដេទែមីណង់ស្មើគ្នា គេបាន

$$\det(B)=\det(P^{-1}AP)=\det(P^{-1})\det(A)\det(P)$$
$$=\frac{1}{\det(P)}\det(A)\det(P)=\det(A)$$ ។

តារាង1 ភាពសមមូល

| លក្ខណៈ | ការពណ៌នា |
|---|---|
| ដេទែមីណង់ | $A$ និង $P^{-1}AP$ មានដេទែមីណង់ដូចគ្នា |
| ភាពប្រាស | $A$ មានភាពប្រាស ប្រសិនបើ $P^{-1}AP$ ប្រាស |
| រ៉ង់ | $A$ និង $P^{-1}AP$ មានរ៉ង់ដូចគ្នា |
| ភាពគ្មានតម្លៃ | $A$ និង $P^{-1}AP$ គ្មានតម្លៃដូចគ្នា |
| គន្លង | $A$ និង $P^{-1}AP$ មានគន្លងដូចគ្នា |
| ពហុធាសម្គាល់ | $A$ និង $P^{-1}AP$ មានពហុធាសម្គាល់ដូចគ្នា |
| តម្លៃផ្ទាល់ | $A$ និង $P^{-1}AP$ មានតម្លៃផ្ទាល់ដូចគ្នា |
| ទំហំលំហផ្ទាល់ | បើ $\lambda$ ជាតម្លៃផ្ទាល់នៃ $A$ ហើយ $P^{-1}AP$ នោះលំហផ្ទាល់នៃ $\lambda$ ហើយលំហផ្ទាល់នៃ $P^{-1}AP$ ត្រូវគ្នានឹង $\lambda$ មានទំហំស្មើគ្នា។ |

## និយមន័យ២

> ម៉ាទ្រីសការេ $A$ មួយអាចធ្វើអង្កត់ទ្រូងកម្មបាន បើវាដូចគ្នាទៅនឹងម៉ាទ្រីសអង្កត់ទ្រូងណាមួយ។ មានន័យថា ម៉ាទ្រីស $P$ ដែលមានម៉ាទ្រីសច្រាស $P^{-1}AP$ ជាម៉ាទ្រីសអង្កត់ទ្រូង។ ក្នុងករណីនេះគេថា ម៉ាទ្រីស $P$ អង្កត់ទ្រូងកម្ម $A$

## ទ្រឹស្ដីបទ

> បើ ម៉ាទ្រីសការេ $A$ មានទំហំ $n\times n$ នោះសំណើរខាងក្រោម សមមូលគ្នា។
> ក. $A$ អាចធ្វើអង្កត់ទ្រូងកម្មបាន។
> ខ. $A$ មាន $n$ វ៉ិចទ័រផ្ទាល់ដែលមិនអាស្រ័យលីនេអ៊ែរ។

ជំហានដំបូង កាត់បន្ថយប្រព័ន្ធសមីការឲ្យទៅជាទំរង់ Echelon ដោយអនុវត្តប្រមាណវិធីដូចខាងក្រោម « ជំនួស $L_1$ ដោយ $-2L_1+L_2$ » ហើយជំនួស $L_3$ ដោយ$-5L_1+L_3$ » បន្ទាប់មក ជំនួស $L_3$ ដោយ $-2L_2+L_3$ »

ប្រមាណវិធីខាងលើបានលទ្ធផលគឺ

$$\begin{aligned} x_1+2x_2-3x_3+2x_4-4x_5&=0\\ x_3+3x_4+2x_5&=0\\ 2x_3-6x_4+4x_5&=0\end{aligned} \quad \text{និង} \quad \begin{aligned} x_1+2x_2-3x_3+2x_4-4x_5&=0\\ x_3+3x_4+2x_5&=0\end{aligned}$$

ប្រព័ន្ធនៅក្នុងទម្រង់ Echelon មានអថេរសេរីចំនួនបី $x_2, x_4, x_5$

ដូច្នេះ $mW=3$ចម្លើយជាវ៉ិចទ័របីដែលបង្កបានជាគោលមួយនៃ W ត្រូវបានទាញបានដូចខាងក្រោម៖

(1). យក $x_2=1, x_4=0, x_5=0$ ជំនួសសមីការ ហើយទាញបានចម្លើយ $u_1=(-2,1,0,0,0)$

(2). យក $x_2=0, x_4=1, x_5=0$ ជំនួសសមីការ ហើយទាញបានចម្លើយ $u_2=(7,0,3,1,0)$

(3). យក $x_2=0, x_4=0, x_5=1$ ជំនួសសមីការ ហើយទាញបានចម្លើយ $u_3=(-2,0,-2,0,1)$

វ៉ិចទ័រ $u_1=(-2,1,0,0,0)$ ,$u_2=(7,0,3,1,0)$ , $u_3=(-2,0,-2,0,1)$បង្កបានជាគោលមួយនៃ W ។

ចំណាំ

ចម្លើយណាមួយនៃប្រព័ន្ធនៅក្នុងឧទាហរណ៍ 3.18 អាចសរសេរជាទម្រង់

$$\begin{aligned} au_1+bu_2+cu_3&=a(-2,1,0,0,0)+b(7,0,3,1,0)+c(-2,0,-2,0,1)\\ &=(-2a+7b-2c,\ a,\ 3b-2c,\ b,\ c)\end{aligned}$$

ឬ $x_1=-2a+7b-2c,\ x_2=a,\ x_3=3b-2c,\ x_4=b,\ x_5=c$

ដែល a, b, c ជាចំនួនថេរណាមួយ ។ សង្កេតថា ការសរសេរខាងលើគឺជាការសរសេរជាទម្រង់ប៉ារ៉ាមែត្រនៃចម្លើយទូទៅក្រោមជម្រើសប៉ារ៉ាម៉ែត្រ $x_2=a, x_4=b, x_5=c$ ។

### ៤.២.២. ប្រព័ន្ធសមីការមិនអូម៉ូសែន និងទំនាក់ទំនងអូម៉ូសែន

តាង $AX = B$ ជាប្រព័ន្ធសមីការមិនអូម៉ូសែននៃសមីការលីនេអ៊ែរ។ នោះ $AX = 0$ ហៅថាប្រព័ន្ធសមីការទំនាក់ទំនងអូម៉ូសែន ។ ជាឧទាហរណ៍៖

$$\begin{matrix} x+2y-4z=7 \\ 3x-5y+6z=8 \end{matrix} \quad \text{និង} \quad \begin{matrix} x+2y-4z=0 \\ 3x-5y+6z=0 \end{matrix}$$

បានបង្ហាញថាប្រព័ន្ធមិនអ៊ូម៉ូសែនមួយ និងប្រព័ន្ធទំនាក់ទំនងអ៊ូម៉ូសែនរបស់វា ។

ទំនាក់ទំនងរវាងចម្លើយ $U$ នៃប្រព័ន្ធមិនអ៊ូម៉ូសែន $AX = B$ និងចម្លើយ $W$ នៃប្រព័ន្ធទំនាក់ទំនងអ៊ូម៉ូសែនរបស់វា $AX = 0$មាននៅក្នុងទ្រឹស្តីបទខាងក្រោម។

**ទ្រឹស្តីបទ៣.១៥** តាង $v_0$ ជាចម្លើយពិសេសមួយនៃ $AX = B$ ហើយតាង W ជាចម្លើយទូទៅនៃ $AX = 0$ ។ នោះខាងក្រោមគឺជាចម្លើយទូទៅនៃ $AX = B$:

$$U = v_0 + W = \{v_0 + w : w \in W\}$$



# ជំពូកទី៥ អនុគមន៍លីនេអ៊ែរ លំហឌុល

## ៥.១. សេចក្តីផ្តើម

នៅក្នុងជំពូកនេះ យើងសិក្សារូបភាពបន្ទាត់លីនេអ៊ែរ ពីទំហំវ៉ិចទ័រ $V$ ទៅក្នុងកាយ $K$ នៃទំហំស្កាលែរ របស់វា។ ក្នុងធម្មជាតិទ្រឹស្តីបទទាំងអស់ និងលទ្ធផលសម្រាប់រូបភាពបន្ទាត់លីនេអ៊ែរដោយមានឥទ្ធិពលលើ $V$ សម្រាប់ករណីពិសេសនេះ។ ទោះយ៉ាងណាក៏ដោយ យើងចាត់ទុករូបភាពបន្ទាត់លីនេអ៊ែរទាំងនេះ

ដោយឡែកពីគ្នា ដោយសារតែសារៈសំខាន់ជាមូលដ្ឋានរបស់ពួកគេ និងដោយសារតែទំនាក់ទំនងពិសេសនៃ $V$ ទៅកាយ $K$ រូបភាពបន្ទាត់លីនេអ៊ែរ ផ្តល់ឱ្យភាពបង្កើនការយល់ឃើញ និងលទ្ធផលថ្មីដែលមិនអនុវត្តនៅក្នុងករណីទូទៅ។

## ៥.២.អនុគមន៍លីនេអ៊ែរ និង លំហឌុល

### ៥.២.១.អនុគមន៍លីនេអ៊ែរ

តាង $V$ ជាលំហវ៉ិចទ័រលើកាយ $K$ មួយ។ រូបភាព $\phi : V \to K$ ត្រូវបានគេហៅថា**អនុគមន៍លីនេអ៊ែរ** (ឬទម្រង់លីនេអ៊ែរ)ប្រសិនបើគ្រប់វ៉ិចទ័រ $u, v \in V$ គ្រប់ $a, b \in K$ ៖

$\phi(au+bv) = a\phi(u) + b\phi(v)$

ម្យ៉ាងវិញទៀត **អនុគមន៍លីនេអ៊ែរ** នៅលើ $V$ គឺជារូបភាពបន្ទាត់លីនេអ៊ែរពី $V$ ទៅ $K$ ។

ឧទាហរណ៍១.១

តាង $\pi_i : K^n \to K$ គឺជារូបភាពទី $i$ កំណត់ដោយ $\pi_i(a_1, a_2, ..., a_n) = a_i$ ។ នោះ $\pi_i$ គឺលីនេអ៊ែរ

ដូចនេះ $\pi_i(a_1, a_2, ..., a_n) = a_i$ ជាអនុគមន៍លីនេអ៊ែរ $K^n$ ។

ឧទាហរណ៍១.២

តាង $V$ គឺជាលំហវ៉ិចទ័រនៃពហុធាមានអថេរ $t$ កំណត់លើ $R$ ។តាង $J : V \to R$ គឺអាំងតេក្រាល $J(p(t)) = \int_0^1 p(t)\,dt$ នោះ $J$ គឺលីនេអ៊ែរ

ដូចនេះ $J$ ជាអនុគមន៍លីនេអ៊ែរលើ $V$ ។

ឧទាហរណ៍១.៣

តាង $V$ គឺជាលំហវ៉ិចទ័រនៃម៉ាទ្រីសការេលំដាប $n$ កំណត់លើកាយ $K$ ។តាង $T : V \to K$ គឺជារូបភាពផលបូកអង្កត់ទ្រូង $T(A) = a_{11} + a_{22} + .... + a_{ij}$ ដែល $A = [a_{ij}]$

នោះគឺ $T$ កំណត់ដោយផលបូកនៃធាតុអង្កត់ទ្រូងម៉ាទ្រីស $A$ ។ $T$ មានទម្រង់ជាលីនេអ៊ែរ

ដូច្នេះ វាគឺជាអនុគមន៍លីនេអ៊ែរលើ $V$

## ៥.២.២. លំហឌុល

សំណុំអនុគមន៍លីនេអ៊ែរលើលំហវ៉ិចទ័រ $V$ នៅលើកាយ $K$ គឺជាលំហវ៉ិចទ័រលើ $K$ ផងដែរ ដែលមានផលបូកនិងផលគុណស្កាលែរ កំណត់ដោយ៖

$$(\phi+\sigma)(v)=\phi(v)+\sigma(v)$$

$$(k\phi)(v)=k\phi(v)$$

ដែល $\phi$ និង $\sigma$ អនុគមន៍លីនេអ៊ែរលើលំហវ៉ិចទ័រ $V$ ហើយ $k\in K$ ។លំហនេះ គេហៅថា **លំហឌុល** តាងអក្សរ $V^*$

ឧទាហរណ៍២.១

តាង $V=K^n$ គឺជាលំហវ៉ិចទ័រនៃ $n-tuple$ យើងកំណត់វ៉ិចទ័រជួរឈរ។ លំហឌុល $V^*$ កំណត់លំហវ៉ិចទ័រជួរដេក។អនុគមន៍លីនេអ៊ែរ $\phi=(a_1,a_2,.....,a_n)$ ក្នុង $V^*$ គឺជារូបភាពតំណាងដោយ៖

$$\phi(x_1,x_2,...,x_n)=[a_1,a_2,...,a_n][x_1,x_2,...,x_n]^T=x_1a_1+x_2a_2+....+x_na_n$$

កន្សោមរូបមន្តនៅខាងលើត្រូវបានគេហៅថា ទម្រង់លីនេអ៊ែរ។

## ៥.៥. ប្រមាណវិធីធ្វើឲ្យសូន្យ

យើងតាង $W$ ជាសំណុំរងនៃលំហវ៉ិចទ័រ $V$ (មិនចាំបាច់លំហរងទេ)។អនុគមន៍ $\phi\in V^*$ ជាអនុគមន៍លីនេអ៊ែរមួយ ត្រូវបានគេហៅថា **ប្រមាណវិធីធ្វើឲ្យសូន្យ នៃ** $W$ ប្រសិនបើ $\phi(w)=0$ គ្រប់ $w\in W$ មានន័យថា ប្រសិនប់គ្រប់ $\phi(W)=\{0\}$ ។ដែលបង្ហាញយើងថា សំណុំនៃរូបភាពតំណាងទាំងអស់នោះកំណត់ដោយ $W^0$ ហើយយើងហៅថា**វិធីធ្វើឲ្យសូន្យ** នៃ $W$ ហើយវាក៏ជាលំហរងមួយរបស់ $V^*$ ។បញ្ជាក់កាន់តែច្បាស់ $0\in W^0$ ។

ឥឡូវយើងឧបមាថា $\phi,\sigma\in W^0$ មានតម្លៃស្កាលែរ $a,b\in K$ និងមាន $w\in W$

$$(a\phi+b\sigma)(w)=a\phi(w)+b\sigma(w)=a0+b0=0$$

ដូចនេះ $(a\phi+b\sigma)\in w^0$ ហើយ $W^0$ ជាលំហរងនៃ $V^*$

ក្នុងករណី $W$ ជាលំហរងនៃ $V$ យើងមានទំនាក់ទំនងដូចខាងក្រោមរវាង $W$ និង**វិធីធ្វើឲ្យសូន្យ** $W^0$ របស់វា។

**<u>ទ្រឹស្តីបទ ៥.៥.</u>**

ឧបមាថា $V$ មានវិមាត្រអាចកំណត់បាន ហើយ $W$ គឺជាលំហរងមួយរបស់ $V$ នោះយើងបាន៖

$i \qquad \dim W+\dim W^0=\dim V$

$ii \qquad W^{00}=\left(w^0\right)^0=W$

ដែល $W^{00}=\{v\in V:\phi(v)=0 \qquad \forall\phi\in W^0\}$ ដែល $W^{00}$ ជាផ្នែកស្ថិតក្នុងលំហរង $V$ ។

សម្រាប់បញ្ជាក់

$i \quad \dim W+\dim W^0=\dim V$

ឧបមាថាមាន $\dim V=n$ ហើយ $\dim V=r\le n$

យើងនឹងបង្ហាញថា $\dim W^0 = n-r$ ដោយយកសំណុំគោល $\{w_1, w_2, ... w_r\}$ របស់ $W$ និងបង្ហាញថាវាជាគោលរបស់ $V$ មានសំណុំ $\{w_1, w_2, ... w_r, v_1, v_2 .... v_{n-1}\}$

យើងពិនិត្យ គោលរបស់ឌុល

$$\{\phi_1, \phi_2 ... \phi_r, \sigma_1, ....., \sigma_{n-r}\}$$

តាមនិយមន័យ គោលឌុល គ្រប់ប្រមាណវិធីធ្វើឲ្យសូន្យរបស់ $\sigma$ ជារបស់ $w_i$ នោះ $\sigma_1 .... \sigma_{n-r} \in W^0$ ។ បញ្ជាក់ថា $\{\sigma_i\}$ គឺជាគោលរបស់ $W^0$ ឥឡូវ $\{\sigma_j\}$ ជាផ្នែកនៃ $V^*$ ហើយដូននេះវាអាស្រ័យលីនេអ៊ែរ។

$$\sigma = \sigma(w_1)\phi_1 + ... + \sigma(w_r)\phi_r + \sigma(v_1)\sigma_1 + ..... + \sigma(v_{n-r})\sigma_{n-r}$$

$$\sigma = 0\phi_1 + ... + 0\phi_r + \sigma(v_1)\sigma_1 + ..... + \sigma(v_{n-r})\sigma_{n-r}$$

$$\sigma = \sigma(v_1)\sigma_1 + ..... + \sigma(v_{n-r})\sigma_{n-r}$$

ដូចនេះ $\{\sigma_1, ..., \sigma_{n-1}\}$ ជាសំណុំបង្ក(spans)និងជាគោលនៃ $W^0$ ។តាមសម្រាយខាងលើគេបាន

$$\dim W^0 = n - r = \dim V - \dim W$$

$$\dim W + \dim W^0 = \dim V$$

$ii$ $\quad W^{00} = \left(w^0\right)^0 = W$

ឧបមាថាមាន $\dim V = n$ ហើយ $\dim W = r$ នោះ $\dim V^* = n$ ហើយតាមការស្រាយបញ្ជាក់( $i$ )

$$\dim W^0 = n - r$$

$$\dim W^{00} = n - (n-1) = r$$

$$\dim W^{00} = \dim W$$

$$\Rightarrow W^{00} = W$$

## ៥.៣. គោលលំហឌុល

សន្មត់ថា $V$ គឺជាលំហវ៉ិចទ័រនៃ $n$ វិមាត្រនៅលើ $K$ ។ យោងតាមទ្រឹស្តីបទ 5.11 វិមាត្រនៃលំហរទ្វេ $V^*$ ក៏ជា $n$ វិមាត្រដែរ( ពីព្រោះ $K$ មានវិមាត្រ 1 នៅលើខ្លួនវាផ្ទាល់ )។ ជាក់ស្តែង គ្រប់មូលដ្ឋាននៃ $V$ នីមួយៗកំណត់បាន $V^*$ មូលដ្ឋានមួយដូចខាងក្រោម( មើលលំហាត់ 11.3 សម្រាប់ការសម្រាយបញ្ជាក់ ) ។

**ទ្រឹស្តីបទ** 5.1 សន្មត់ថា $\{v_1, ..., v_n\}$ ជាគោលមួយរបស់ $V$ នៅលើ $K$ ។ តាង $\phi_1, ..., \phi_n \in V^*$ ជាអនុគមន៍លីនេអ៊ែដែលកំណត់ដោយ $\phi_i(v_j) = \delta_{ij} = \begin{cases} 1 \ if \quad i = j \\ 0 \ if \ i \neq j \end{cases}$ នោះ $\{\phi_1, ..., \phi_n\}$ ជាមូលដ្ឋានមួយរបស់ $V^*$ ។

គោល $\{\phi_i\}$ ខាងលើគឺគេហៅថា គោលលំហឌុល $\{v_1\}$ ។ រូបមន្តខាងលើ ដែលជា ការប្រើប្រាស់ Kronecker delta $\delta_{ij}$ គឺជាការសរសេរកាត់

$$\phi_1(v_1)=1,\ \phi_1(v_2)=0,\ \phi_1(v_3)=0,\ \dots,\phi_1(v_n)=0$$
$$\phi_2(v_1)=0,\ \phi_2(v_2)=1,\ \phi_2(v_3)=0,\ \dots,\phi_2(v_n)=0$$
$$\dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots$$
$$\phi_n(v_1)=0,\ \phi_n(v_2)=0,\dots,\phi_n(v_{n-1})=0,\ \phi_1(v_n)=1$$

តាមទ្រឹស្តីបទ 5.2 ដែលផែនទីលីនេអ៊ែ $\{\phi_i\}$ ទាំងនេះគឺប្លែក និងកំណត់បានល្អ។

៥.៣. ស្រាយបញ្ជាក់ទ្រឹស្តីបទ 11.1 សន្មត់ថា $\{v_1,\dots,v_n\}$ ជាគោលមួយរបស់ $V$ នៅលើ $K$ ។ តាង $\phi_1,\dots,\phi_n\in V^*$ កំណត់ដោយ $\phi_i(v_j)=0$ ចំពោះ $i\neq j$ ប៉ុន្តែ $\phi_i(v_j)=1$ ចំពោះ $i=j$ ។ នោះ $\{\phi_1,\dots,\phi_n\}$ ជាគោលរបស់ $V^*$ ។

ជាដំបូងយើងបង្ហាញថា $\{\phi_1,\dots,\phi_n\}$ ស្ប៉ាន $V^*$ ។ តាង $\phi$ ជាធាតុរបស់ $V^*$ និងសន្មត់ថា

$$\phi(v_1)=k_1,\qquad \phi(v_2)=k_2,\quad \dots\dots\qquad \phi(v_n)=k_n$$

យក $\sigma=k_1\phi_1+\dots+k_n\phi_n$ គេបាន

$$\sigma(v_1)=(k_1\phi_1+\dots+k_n\phi_n)(v_1)=k_1\phi_1(v_1)+k_2\phi_2(v_2)+\dots+k_n\phi_n(v_1)=k_1\cdot1+k_2\cdot0+\dots+k_n\cdot0=k_1$$

ដូចគ្នាដែរចំពោះ $i=2,\dots,n,$

$$\sigma(v_i)=(k_1\phi_1+\dots+k_n\phi_n)(v_i)=k_1\phi_1(v_i)+\dots+k_i\phi_i(v_i)+\dots+k_n\phi_n(v_i)=k_i$$

ដូចនេះ $\phi(v_i)=\sigma(v_i)$ ចំពោះ $i=1,\dots,n$ ។ ពីព្រោះ $\phi$ និង $\sigma$ ត្រូវគ្នានៅលើគោលវិចទ័រដែល $\phi=\sigma=k_1\phi_1+\dots+k_n\phi_n$ គេទាញបានថា $\{\phi_1,\dots,\phi_n\}$ ស្ប៉ាន $V^*$ ។

វាសំខាន់ដែលត្រូវស្រាយឱ្យឃើញថា $\{\phi_1,\dots,\phi_n\}$ គឺមិនអាស្រ័យលីនេអ៊ែរ។ សន្មត់ថា

$$a_1\phi_1+a_2\phi_2+\dots+a_n\phi_n=0$$

គុណអង្គសងខាងនឹង $v_1$ យើងបាន

$$0=0(v_1)=(a_1\phi_1+\dots+n_n\phi_n)(v_1)=a_1\phi_1(v_1)+a_2\phi_2(v_1)+\dots+a_n\phi_n(v_1)=a_1\cdot1+a_2\cdot0+\dots+a_n\cdot0=a_1$$

ដូចគ្នាដែរចំពោះ $i=2,\dots,n,$

$$0=0(v_i)=(a_1\phi_1+\dots+a_n\phi_n)(v_i)=a_1\phi_1(v_i)+\dots+a_i\phi_i(v_i)+\dots+a_n\phi_n(v_i)=a_i$$

ដូចនេះ $a_1=0,\dots,a_n=0$ ។ ដូច្នេះ $\{\phi_1,\dots,\phi_n\}$ គឺមិនអាស្រ័យលីនេអ៊ែរ ហើយ $\{\phi_1,\dots,\phi_n\}$ ជាគោលនៃ $V^*$ ។

**ឧទាហរណ៍** 5.3 គេមានមូលដ្ឋាន $\{v_1=(2.1),\ v_2=(3,1)\}$ នៅលើ $\mathbb{R}^2$ ។ រកមូលដ្ឋានទ្វេ $\{\phi_1,\phi_2\}$ ។

យើងស្វែងរកអនុគមន៍លីនេអ៊ែ $\phi_1(x,y)=ax+by$ និង $\phi_2(x,y)=cx+dy$ ដែល $\phi_1(v_1)=1,\ \phi_1(v_2)=0,\ \phi_2(v_1)=0,\ \phi_2(v_2)=1$ ចំពោះលក្ខខណ្ឌទាំងបួននេះនាំឱ្យយើងបានប្រព័ន្ធសមីការដូចខាងក្រោម

$$\left.\begin{array}{l}\phi_1(v_1)=\phi_1(2,1)=2a+b=1\\ \phi_1(v_2)=\phi_1(3,1)=3a+b=0\end{array}\right\}\ \text{និង}\ \left.\begin{array}{l}\phi_2(v_1)=\phi_2(2,1)=2c+d=0\\ \phi_2(v_2)=\phi_2(3,1)=3c+d=1\end{array}\right\}$$

ដំណោះស្រាយ រកឃើញថា $a=-1,b=3$ និង $c=1,d=-2$ ។ ដូច្នេះហើយ $\phi_1(x,y)=-x+3y$ និង $\phi_2(x,y)=-x-2y$ ដែលជាទម្រង់នៃមូលដ្ឋានទ្វេ។

ទ្រឹស្តីបទពីរខាងក្រោម ( បានស្រាយបញ្ជាក់នៅក្នុងលំហាត់ 11.4 និង 11.5 រៀងគ្នា) ដែលផ្តល់ទំនាក់ទំនងរវាងមូលដ្ឋាន និងទ្វេររបស់ទ្រឹស្តីបទទាំងពីរ។

**ទ្រឹស្តីបទ** 5.2៖ តាង $\{v_1,...,v_n\}$ ជាមូលដ្ឋានមួយរបស់ $V$ និងតាង $\{\phi_1,...,\phi_n\}$ ជាមូលដ្ឋានទ្វេរនៅក្នុង $V^*$ ។ នោះ

$(i)$ ចំពោះវ៉ិចទ័រ $u\in V$ ដែល $u=\phi_1(u)v_1+\phi_2(u)v_2+...+\phi_n(u)v_n$ ។

$(ii)$ ចំពោះអនុគមន៍លីនេអ៊ែរ $\sigma=\sigma(v_1)\phi_1+\sigma(v_2)\phi_2+...+\sigma(v_n)\phi_n$ ។

## ស្រាយបញ្ជាក់ទ្រឹស្តីបទ

តាង $\{v_1`,...,v_n\}$ ជាគោលនៃ $V$ និងតាង $\{\phi_1,...,\phi_n\}$ ជាគោលឌុយអាល់ក្នុង $V^*$ ។គ្រប់ $u\in V$ និង $\sigma\in V^*$ $(i)$ $u=\sum_i \phi_i(u)v_i$, $(ii)$ $\sigma=\sum_i \phi(v_i)\phi_i$,

សន្មត់ថា $u=a_1v_1+a_2v_2+...+a_nv_n$

នោះ $\phi_1(u)=a_1\phi_1(v_1)+a_2\phi_2(v_2)+...+a_n\phi_n(v_n)=a_1\cdot 1+a_2\cdot 0+...+a_n\cdot 0=a_1$

ដូចគ្នាដែរ $i=2,....,n$

$\phi_i(u)=a_1\phi_i(v_1)+...+a_i\phi_i(v_i)+a_n\phi_i(v_n)=a_i$

គេបាន $\phi_1(u)=a_1,\phi_2(u)=a_2,...,\phi_n(u)=a_n$ ជំនួសចម្លើយក្នុងសមីការ $(1)$ គេបាន $(i)$

ជំហានបន្ទាប់បង្ហាញ $(ii)$ គុណអនុគមន៍លីនេអ៊ែរ $\sigma$ ទៅអង្គសងខាងនៃ $(i)$

$$\begin{aligned}\sigma(u)&=\phi_1(u)\sigma(v_1)+\phi_2(u)\sigma(v_2)+...+\phi_n(u)\sigma(v_n)\\&=\sigma(v_1)\phi_1(u)+\sigma(v_2)\phi_2(u)+...+\sigma(v_n)\phi_n(u)\\&=(\sigma(v_1)\phi_1+\sigma(v_2)\phi_2+...+\sigma(v_n)\phi_n)(u)\end{aligned}$$

ពីព្រោះគ្រប់ $u\in V,\sigma=\sigma(v_1)\phi_2+\sigma(v_2)\phi_2+...+\sigma(v_n)\phi_n$ ។

**ទ្រឹស្តីបទ** 5.3៖ តាង $\{v_1,...,v_n\}$ និង $\{w_1,...,w_n\}$ ជាមូលដ្ឋានមួយរបស់ $V$ ហើយតាង $\{\phi_1,...,\phi_n\}$ និង $\{\sigma_1,...,\sigma_n\}$ ជាមូលដ្ឋាននៅក្នុង $V^*$ ទ្វេរទៅ $\{v_i\}$ និង $\{w_i\}$ រៀងគ្នា។ សន្មាត់ថា $P$ ជាម៉ាទ្រីសប្តូរគោល ពី $\{v_i\}$ ទៅ $\{w_i\}$ ។ នោះ $(P^{-1})^{\tau}$ គឺជាម៉ាទ្រីស change-of-basis ពី $\{\phi_i\}$ ទៅ $\{\sigma_i\}$ ។

## ស្រាយបញ្ជាក់ទ្រឹស្តីបទ

តាង $\{v_i\}$ និង $\{w_i\}$ ជាគោលនៃ $V$ និងតាង $\{\phi_i\}$ និង $\{\sigma_i\}$ ជាគោលឌុយអាល់ក្នុង $V^*$ ។តាង $P$ ជាទម្រង់ប្តូរគោលម៉ាទ្រីសពី $\{v_i\}$ ទៅ $\{w_i\}$ ។នោះ $(P^{-1})^T$ ជាទម្រង់ប្តូរគោលម៉ាទ្រីសពី $\{\phi_i\}$ ទៅ $\{\sigma_i\}$ ។

សន្មត់ថា $i=1,....,n$

$w_i=a_{i1}v_1+a_{i2}v_2+...+a_{in}v_n$ និង $\sigma_i=b_{i1}\phi_1+b_{i2}\phi_2+...+a_{in}v_n$

គេបាន $P=[a_{ij}]$ និង $Q=[b_{ij}]$ ។ យើងត្រូវបង្ហាញថា $Q=(P^{-1})^T$

តាង $R_i$ កំណត់ជួរដេកទី $i$ នៃ $Q$ និង $C_j$ កំណត់ជួរឈរទី $j$ នៃ $P^T$ ។ គេបាន

$R_i=(b_{i1},b_{i2},...,b_{in})$ និង $C_j=(a_{j1},a_{j2},...,a_{jn})^T$

តាមនិយមន័យគោលឌុយអាល់

$$\sigma_i(w_j)=(b_{i1}\phi_1+b_{i2}\phi_2+...+b_{in}\phi_n)(a_{j1}v_1+a_{j2}v_2+...+a_{jn}v_n)$$
$$=b_{i1}a_{j1}+b_{i2}a_{j2}+...+b_{in}a_{jn}=R_iC_j=\delta_{ij}$$

ដែល $\delta_{ij}$ ជាដេលតាក្រូណេក័រ។ ដូច្នេះ $QP^T=[R_iC_j]=[\delta_{ij}]=I$

ដូចនេះ $Q=(P^T)^{-1}=(P^{-1})^T$ ។

ស្រាយបញ្ជាក់ទ្រឹស្តីបទ 11.1 សន្មត់ថា $\{v_1,...,v_n\}$ ជាមូលដ្ឋានមួយរបស់ $V$ នៅលើ $K$ ។ តាង $\phi_1,...,\phi_n\in V^*$ កំណត់ដោយ $\phi_i(v_j)=0$ ចំពោះ $i\neq j$ ប៉ុន្តែ $\phi_i(v_j)=1$ ចំពោះ $i=j$ ។ នោះ $\{\phi_1,...,\phi_n\}$ ជាមូលដ្ឋានទ្វេររបស់ $V^*$ ។

ជាដំបូងយើងបង្ហាញថា $\{\phi_1,...,\phi_n\}$ នៅក្នុង $V^*$ ។ តាង $\phi$ ជាធាតុរបស់ $V^*$ និងសន្មត់ថា

$$\phi(v_1)=k_1,\qquad \phi(v_2)=k_2,\quad .....\qquad \phi(v_1)=k_1,$$

យក $\sigma=k_1\phi_1+...+k_n\phi_n$ គេបាន

$$\sigma(v_1)=(k_1\phi_1+...+k_n\phi_n)(v_1)=k_1\phi_1(v_1)+k_2\phi_2(v_2)+...+k_n\phi_n(v_1)=k_1\cdot 1+k_2\cdot 0+...+k_n\cdot 0=k_1$$

ដូចគ្នាដែរចំពោះ $i=2,...,n,$

$$\sigma(v_i)=(k_1\phi_1+...+k_n\phi_n)(v_i)=k_1\phi_1(v_i)+...+k_i\phi_i(v_i)+...+k_n\phi_n(v_i)=k_i$$

ដូចនេះ $\phi(v_i)=\sigma(v_i)$ ចំពោះ $i=1,....,n$ ។ ពីព្រោះ $\phi$ និង $\sigma$ ត្រូវគ្នានៅលើវ៉ិចទ័រមូលដ្ឋានដែល $\phi=\sigma=k_1\phi_1+...+k_n\phi_n$ គេទាញបានថា $\{\phi_1,...,\phi_n\}$ នៅក្នុង $V^*$ ។

វាសំខាន់ដែលត្រូវស្រាយឱ្យឃើញថា $\{\phi_1,...,\phi_n\}$ ជាលីនេអ៊ែឯករាជ្យ។ សន្មត់ថា

$$a_1\phi_1+a_2\phi_2+...+a_n\phi_n=0$$

គុណអង្គសងខាងនឹង $v_1$ យើងបាន

$$0=0(v_1)=(a_1\phi_1+...+n_n\phi_n)(v_1)=a_1\phi_1(v_1)+a_2\phi_2(v_1)+...+a_n\phi_n(v_1)=a_1\cdot 1+a_2\cdot 0+...+a_n\cdot 0=a_1$$

ដូចគ្នាដែរចំពោះ $i=2,...,n,$

$$0=0(v_i)=(a_1\phi_1+...+a_n\phi_n)(v_i)=a_1\phi_1(v_i)+...+a_i\phi_i(v_i)+...+a_n\phi_n(v_i)=a_i$$

ដូចនេះ $a_1=0,...,a_n=0$ ។ ដូច្នេះ $\{\phi_1,...,\phi_n\}$ ជាលីនេអ៊ែឯករាជ្យ ហើយ $\{\phi_1,...,\phi_n\}$ ជាមូលដ្ឋាននៃ $V^*$ ។

## ៥.៤. លំហាឌុលទី២ ( Second Dual Space )

**ពិនិត្យឡើងវិញ៖** គ្រប់លំហវ៉ិចទ័រ $V$ មានលំហឌុយអាល់ $V^*$ ដែលមានអនុគមន៍លីនេអ៊ែរទាំងអស់នៅលើ $V$ ដូចនេះ $V^*$ មានលំហឌុយអាល់ $V^{**}$ ហៅថាលំហឌុយអាល់ទី២នៃ $V$ ដែលមានអនុគមន៍លីនេអ៊ែរទាំងអស់នៅលើ $V^*$ ។

យើងនឹងបង្ហាញថាគ្រប់ $v \in V$ កំណត់គ្រប់ធាតុជាក់លាក់មួយ $\hat{v} \in V^{**}$ ។ ដំបូងចំពោះ $\phi \in V^*$ កំណត់ $v(\phi) = \phi(v)$ ។

វាត្រូវបានបង្ហាញក្នុងអនុវត្តន៍ $\hat{v}: V^* \to K$ គឺលីនេអ៊ែរ។ សម្រាប់ទំហំស្កាលែ $a, b \in K$ និងអនុគមន៍ $\phi, \sigma \in V^*$

យើងបាន $\hat{v}(a\phi + b\sigma) = (a\phi + b\sigma)(v) = a\phi(v) + b\phi(v) = a\hat{v}(\phi) + b\hat{v}(\sigma)$

នោះ $\hat{v}$ គឺលីនេអ៊ែរ ដូចនេះ $\hat{v} \in V^{**}$ ទ្រឹស្តីបទខាងក្រោម(បង្ហាញក្នុងលំហាត់12.7)។

**ទ្រឹស្តីបទ5.4៖** បើ $V$ មានវិមាត្រកំណត់ អនុវត្តន៍ $v \mapsto \hat{v}$ គឺអ៊ីសូម៉ូភីសនៃ $V$ លើ $V^{**}$ ។

អនុវត្តន៍ខាងលើ $v \mapsto \hat{v}$ ហៅថា អនុវត្តន៍ធម្មជាតិនៃ $V$ លើ $V^{**}$ ។ យើងកំណត់ថាអនុវត្តន៍នេះនឹងមិននៅលើ $V^{**}$ បើ $V$ មានវិមាត្រមិនកំណត់ ទោះជាយ៉ាងណាវានៅតែលីនេអ៊ែរ មិនតែប៉ុណ្ណោះវាតែងតែជាអនុវត្តន៍មួយទល់មួយ។

ឥឡូវយើងសន្មតថា $V$ មានវិមាត្រកំណត់។ ដោយប្រើទ្រឹស្តីបទ11.4 ។ អនុវត្តន៍ធម្មជាតិកំណត់អ៊ីសូម៉ូភីសរវាង $V$ លើ $V^{**}$ លុះត្រាតែបានលើកឡើង នោះយើងនឹងកំណត់ $V$ ជាមួយ $V^{**}$ ដោយប្រើអនុវត្តន៍នេះ។

តាមលក្ខខណ្ឌខាងលើយើងនឹងបង្ហាញ $V$ គឺជាលំហនៃអនុគមន៍លីនេអ៊ែរនៅលើ $V^{**}$ ហើយសរសេរ $V = V^{**}$ យើងត្រូវកត់សម្គាល់ថា បើ $\{\phi_i\}$ គឺជាគោលនៃ $V^*$ ឌុយអាល់ទៅនឹងគោល $\{v_i\}$ នៃ $V$
នោះ $\{v_i\}$ គឺជាគោលនៃ $V^{**} = V$ ដែលឌុយអាល់ទៅនឹង $\{\phi_i\}$ ។

## ៥.៦. រូបភាពបម្លែងលីនេអ៊ែរ

តាង $T: V \to U$ ជារូបភាពលីនេអ៊ែរសេរីចន្លោះ លំហវ៉ិចទ័រ $V$ ទៅក្នុងលំហវ៉ិចទ័រ $U$ ។ ឥឡូវសម្រាប់អ្វីមួយ។

អនុគមន៍លីនេអ៊ែរ $\phi \in U^*$ មានសមាសភាព $\phi \circ T$ គឺជាការគូសវាសរូបភាពលីនេអ៊ែរពី $V$ ទៅក្នុង $K$ ៖




ដែល $\phi \circ T \in V^*$ នោះទំនាក់ទំនង $\phi \mapsto \phi \circ T$ គឺជារូបភាពពី $U^*$ ក្នុង $V^*$ ។ តាងដោយនិមិត្តញ្ញា $T^t$ ហើយហៅថា បម្លែង $T$ ។ ម្យ៉ាងទៀត $T^t: U^* \to V^*$ កំណតដោយ៖

$$T^t(\phi) = \phi \circ T$$

នោះ $\left(T^t(\phi)\right)(v) = \phi\left(T(v)\right) \qquad \forall v \in V$

**ទ្រឹស្តីបទ ៥.៦.**

បម្លែងរូបភាព $T^t(\phi)=\phi\circ T$ ជាបម្លែងលីនេអ៊ែរ

សម្រាប់បញ្ជាក់

មានតម្លៃស្កាលែរ $a,b\in K$ ហើយនឹងអនុគមន៍លីនេអ៊ែរ $\phi,\sigma\in U^*$

$$T^t(\phi)=\phi\circ T\Rightarrow T^t(a\phi+b\sigma)=(a\phi+b\sigma)\circ T=a(T\circ\phi)+b(T\circ\sigma)=T^t(a)+T^t(b)$$

នេះបញ្ជាក់ថា $T^t(\phi)=\phi\circ T$ គឺលីនេអ៊ែរ

**ទ្រឹស្តីបទ ៥.៧.**

តាង $T:V\to U$ គឺលីនេអ៊ែរ ហើយតាង $A$ ជាម៉ាទ្រីសតំណាងរបស់ $T$ មានទំនាក់ទំនងទៅគោល $\{v_i\}$ របស់ $V$ ហើយនិង $\{u_i\}$ របស់ $U$ ។នោះម៉ាទ្រីសត្រង់ស្ប៉ូ $A^T$ គឺជាម៉ាទ្រីសត្រូវនឹង $T^t:U^*\to V^*$ មានទាក់ទងនឹង គោលឌុល ពីរគឺ $\{v_i\}$ និង $\{u_i\}$ ។

ដំណោះស្រាយ

លំហឌុយអាល់ និងគោលឌុយអាល់

**៥.១.** រកគោល $\{\phi_1,\phi_2,\phi_3\}$ ដែលត្រូវបានឌុយអាល់ទៅនឹងគោលនៃ $\mathbb{R}^3$ :

$$\{v_1=(1,-1,3),v_2=(0,1,-1),v_3=(0,3,-2)\}$$

ទម្រង់អនុគមន៍លីនេអ៊ែរ

$\phi_1(x,y,z)=a_1x+a_2y+a_3z,\ \phi_2(x,y,z)=b_1x+b_2y+b_3z,\ \phi_3(x,y,z)=c_1x+c_2y+c_3z$

ដោយអនុវត្តតាមនិយមន័យនៃគោលឌុយអាល់ $\phi_i(v_j)=0$ ដែល $i\neq j$ តែ $\phi_i(v_j)=1$ ដែល $i=j$

យើងរក $\phi_1$ ដោយកំណត់ $\phi_1(v_1)=1,\phi_1(v_2)=0,\phi_1(v_3)=0$

គេបាន $\phi_1(1,-1,3)=a_1-a_2+3a_3=1,\phi_1(0,1,-1)=a_2-a_3=0,\phi_1(0,3,-2)=3a_2-2a_3=0$

ដោះស្រាយប្រព័ន្ធសមីការ $a_1=1,a_2=0,a_3=0$

ដូចនេះ $\phi_1(x,y,z)=x$ ។

យើងរក $\phi_2$ ដោយកំណត់ $\phi_2(v_1)=0,\phi_2(v_2)=1,\phi_2(v_3)=0$

គេបាន $\phi_2(1,-1,3)=b_1-b_2+3b_3=0,\phi_2(0,1,-1)=b_2-b_3=1,\phi_2(0,3,-2)=3b_2-2b_3=0$

ដោះស្រាយប្រព័ន្ធសមីការ $b_1=7,b_2=-2,b_3=-3$

ដូចនេះ $\phi_2(x,y,z)=7x-2y-3z$ ។

យើងរក $\phi_3$ ដោយកំណត់ $\phi_3(v_1)=0,\phi_3(v_2)=0,\phi_3(v_3)=1$

គេបាន $\phi_3(1,-1,3)=c_1-c_2+3c_3=0,\phi_3(0,1,-1)=c_2-c_3=1,\phi_3(0,3,-2)=3c_2-2c_3=1$

ដោះស្រាយប្រព័ន្ធសមីការ $c_1=-2,c_2=1,c_3=1$

ដូចនេះ $\phi_3(x,y,z)=-2x+y+z$ ។

៥.២. តាង $V=\{a+bt:a,b\in\mathbb{R}\}$ លំហវ៉ិចទ័រនៃដឺក្រេនៃពហុធា $\leq 1$ ។ រកគោល $\{v_1,v_2\}$ នៃ $V$ ដែលត្រូវបានឌុយអាល់ទៅនឹងគោល $\{\phi_1,\phi_2\}$ នៃ $V^*$ កំណត់ដោយ

$$\phi_1(f(t))=\int_0^1 f(t)dt \text{ និង } \phi_2(f(t))=\int_0^2 f(t)dt$$

តាង $v_1=a+bt$ និង $v_2=c+dt$ ។

តាមនិយមន័យនៃគោលឌុយអាល់

$$\phi_1(v_1)=1,\ \phi_1(v_2)=0 \text{ និង } \phi_2(v_1)=0,\ \phi_i(v_j)=1$$

ដូចនេះ

$$\left.\begin{aligned}\phi_1(v_1)&=\int_0^1(a+bt)dt=a+\frac{1}{2}b=1\\ \phi_2(v_1)&=\int_0^2(a+bt)dt=2a+2b=0\end{aligned}\right\} \text{ និង } \left.\begin{aligned}\phi_1(v_2)&=\int_0^1(c+dt)dt=c+\frac{1}{2}d=0\\ \phi_2(v_2)&=\int_0^2(c+dt)dt=2c+2d=1\end{aligned}\right\}$$

ដោះស្រាយប្រព័ន្ធ $a=2,\ b=-2$ និង $c=-\frac{1}{2},\ d=1$ ។ ដូចនេះ $\left\{v_1=2-2t,\ v_2=-\frac{1}{2}+t\right\}$ គឺជាគោលនៃ $V$ ដែលឌុយអាល់ទៅនឹង $\{\phi_1,\phi_2\}$ ។

៥.៣. ស្រាយបញ្ជាក់ទ្រឹស្តីបទ 11.1 សន្មត់ថា $\{v_1,...,v_n\}$ ជាគោលមួយរបស់ $V$ នៅលើ $K$ ។ តាង $\phi_1,...,\phi_n\in V^*$ កំណត់ដោយ $\phi_i(v_j)=0$ ចំពោះ $i\neq j$ ប៉ុន្តែ $\phi_i(v_j)=1$ ចំពោះ $i=j$ ។ នោះ $\{\phi_1,...,\phi_n\}$ ជាគោលរបស់ $V^*$ ។

ជាដំបូងយើងបង្ហាញថា $\{\phi_1,...,\phi_n\}$ ស្ប៉ាន $V^*$ ។ តាង $\phi$ ជាធាតុរបស់ $V^*$ និងសន្មត់ថា

$$\phi(v_1)=k_1,\qquad \phi(v_2)=k_2,\quad .....\qquad \phi(v_n)=k_n$$

យក $\sigma=k_1\phi_1+...+k_n\phi_n$ គេបាន

$$\sigma(v_1)=(k_1\phi_1+...+k_n\phi_n)(v_1)=k_1\phi_1(v_1)+k_2\phi_2(v_2)+...+k_n\phi_n(v_1)=k_1\cdot 1+k_2\cdot 0+...+k_n\cdot 0=k_1$$

ដូចគ្នាដែរចំពោះ $i=2,...,n,$

$$\sigma(v_i)=(k_1\phi_1+...+k_n\phi_n)(v_i)=k_1\phi_1(v_i)+...+k_i\phi_i(v_i)+...+k_n\phi_n(v_i)=k_i$$

ដូចនេះ $\phi(v_i)=\sigma(v_i)$ ចំពោះ $i=1,....,n$ ។ ពីព្រោះ $\phi$ និង $\sigma$ ត្រូវគ្នានៅលើគោលវិចទ័រដែល $\phi=\sigma=k_1\phi_1+...+k_n\phi_n$ គេទាញបានថា $\{\phi_1,...,\phi_n\}$ ស្ប៉ាន $V^*$ ។

វាសំខាន់ដែលត្រូវស្រាយឱ្យឃើញថា $\{\phi_1,...,\phi_n\}$ គឺមិនអាស្រ័យលីនេអ៊ែរ។ សន្មត់ថា

$$a_1\phi_1+a_2\phi_2+...+a_n\phi_n=0$$

គុណអង្គសងខាងនឹង $v_1$ យើងបាន

$$0=0(v_1)=(a_1\phi_1+...+n_n\phi_n)(v_1)=a_1\phi_1(v_1)+a_2\phi_2(v_1)+...+a_n\phi_n(v_1)=a_1\cdot 1+a_2\cdot 0+...+a_n\cdot 0=a_1$$

ដូចគ្នាដែរចំពោះ $i=2,...,n,$

$$0=0(v_i)=(a_1\phi_1+...+a_n\phi_n)(v_i)=a_1\phi_1(v_i)+...+a_i\phi_i(v_i)+...+a_n\phi_n(v_i)=a_i$$

ដូចនេះ $a_1=0,...,a_n=0$ ។ ដូច្នេះ $\{\phi_1,...,\phi_n\}$ គឺមិនអាស្រ័យលីនេអ៊ែរ ហើយ $\{\phi_1,...,\phi_n\}$ ជាគោលនៃ $V^*$ ។

១១.៤. ស្រាយបញ្ជាក់ទ្រឹស្តីបទ១១.២ តាង $\{v_1`,...,v_n\}$ ជាគោលនៃ $V$ និងតាង $\{\phi_1,...,\phi_n\}$ ជាគោលឌុយអាល់ក្នុង $V^*$ ។ គ្រប់ $u\in V$ និង $\sigma\in V^*$ $(i)\ u=\sum_i\phi_i(u)v_i,\ (ii)\ \sigma=\sum_i\phi(v_i)\phi_i,$

សន្មត់ថា $u=a_1v_1+a_2v_2+...+a_nv_n$

នោះ $\phi_1(u)=a_1\phi_1(v_1)+a_2\phi_2(v_2)+...+a_n\phi_n(v_n)=a_1\cdot 1+a_2\cdot 0+...+a_n\cdot 0=a_1$

ដូចគ្នាដែរ $i=2,....,n$

$\phi_i(u)=a_1\phi_i(v_1)+...+a_i\phi_i(v_i)+a_n\phi_i(v_n)=a_i$

គេបាន $\phi_1(u)=a_1,\phi_2(u)=a_2,...,\phi_n(u)=a_n$ ជំនួសចម្លើយក្នុងសមីការ $(1)$ គេបាន $(i)$

ជំហានបន្ទាប់បង្ហាញ $(ii)$ គុណអនុគមន៍លីនេអ៊ែរ $\sigma$ ទៅអង្គសងខាងនៃ $(i)$

$$\sigma(u)=\phi_1(u)\sigma(v_1)+\phi_2(u)\sigma(v_2)+...+\phi_n(u)\sigma(v_n)$$
$$=\sigma(v_1)\phi_1(u)+\sigma(v_2)\phi_2(u)+...+\sigma(v_n)\phi_n(u)$$
$$=(\sigma(v_1)\phi_1+\sigma(v_2)\phi_2+...+\sigma(v_n)\phi_n)(u)$$

ពីព្រោះគ្រប់ $u\in V,\sigma=\sigma(v_1)\phi_2+\sigma(v_2)\phi_2+...+\sigma(v_n)\phi_n$ ។

៥.៥. ស្រាយបញ្ជាក់ទ្រឹស្តីបទ១១.៣ តាង $\{v_i\}$ និង $\{w_i\}$ ជាគោលនៃ $V$ និងតាង $\{\phi_i\}$ និង $\{\sigma_i\}$ ជាគោលឌុយអាល់ក្នុង $V^*$ ។ តាង $P$ ជាទម្រង់ប្តូរគោលម៉ាទ្រីសពី $\{v_i\}$ ទៅ $\{w_i\}$ ។ នោះ $(P^{-1})^T$ ជាទម្រង់ប្តូរគោលម៉ាទ្រីសពី $\{\phi_i\}$ ទៅ $\{\sigma_i\}$ ។

សន្មត់ថា $i=1,....,n$

$w_i=a_{i1}v_1+a_{i2}v_2+...+a_{in}v_n$ និង $\sigma_i=b_{i1}\phi_1+b_{i2}\phi_2+...+a_{in}v_n$

គេបាន $P=[a_{ij}]$ និង $Q=[b_{ij}]$ ។ យើងត្រូវបង្ហាញថា $Q=(P^{-1})^T$

តាង $R_i$ កំណត់ជួរដេកទី $i$ នៃ $Q$ និង $C_j$ កំណត់ជួរឈរទី $j$ នៃ $P^T$ ។ គេបាន

$R_i=(b_{i1},b_{i2},...,b_{in})$ និង $C_j=(a_{j1},a_{j2},...,a_{jn})^T$

តាមនិយមន័យគោលឌុយអាល់

$$\sigma_i(w_j)=(b_{i1}\phi_1+b_{i2}\phi_2+...+b_{in}\phi_n)(a_{j1}v_1+a_{j2}v_2+...+a_{jn}v_n)$$
$$=b_{i1}a_{j1}+b_{i2}a_{j2}+...+b_{in}a_{jn}=R_iC_j=\delta_{ij}$$

ដែល $\delta_{ij}$ ជាដេលតាក្រូណេក័រ។ ដូច្នេះ $QP^T=[R_iC_j]=[\delta_{ij}]=I$

ដូចនេះ $Q=(P^T)^{-1}=(P^{-1})^T$ ។

៥.៦. សន្មតថា $v\in V,v\neq 0$ និង $\dim V=n$ ។ បង្ហាញថាមាន $\phi\in V^*$ ដែល $\phi(v)\neq 0$ ។

យើងពង្រីក $\{v\}$ ទៅជាគោល $\{v_1,v_2,...,v_n\}$ នៃ $V$ ។ តាមទ្រឹស្តីបទ៥.២ មានសមីការលីនេអ៊ែរតែមួយ $\phi:V\to K$ ដែលមាន $\phi(v)=1$ និង $\phi(v_i)=0,\ i=2,...,n$ ។ ដូចនេះ $\phi$ មានលក្ខណៈដែលត្រូវការ។

៥.៧. ស្រាយបញ្ជាក់ទ្រឹស្តីបទ១១.៤. សន្មតថា $\dim V=n$ ។ អនុវត្ត $v\mapsto\hat{v}$ គឺអ៊ីសូម៉ូភីសនៃ $V$ លើ $V^{**}$ ។

ដំបូងបង្ហាញអនុវត្ត $v \mapsto \hat{v}$ គឺលីនេអ៊ែរសម្រាប់ទំហំវ៉ិចទ័រ $v, w \in V$ និងទំហំស្កាលែ $a, b \in K, \widehat{av+bw} = a\hat{v} + b\hat{w}$ ។ គ្រប់អនុគមន៍លីនេអ៊ែរ $\phi \in V^{**}$,

$$\widehat{av+bw}(\phi) = \phi(av+bw) = a\phi(v) + b\phi(w) = a\hat{v}(\phi) + b\hat{w}(\phi) = \left(a\hat{v} + b\hat{w}\right)(\phi)$$

ព្រោះ $\widehat{av+bw}(\phi) = \left(a\hat{v} + b\hat{w}\right)(\phi)$ សម្រាប់គ្រប់ $\phi \in V^*$ ។ យើងមាន $\widehat{av+bw} = a\hat{v} + b\hat{w}$ ។ ដូចនេះ អនុវត្ត $v \mapsto \hat{v}$ គឺលីនេអ៊ែរ។

សន្មតថា $v \in V, v \neq 0$ ។ តាមលំហាត់១១.៦ មាន $\phi \in V^*$ ដែល $\phi(v) \neq 0$ ។ ដូចនេះ $\hat{v}(\phi) = \phi(v) \neq 0$ និង $\hat{v} \neq 0$ ។ ព្រោះ $v \neq 0$ ផ្ទៀងផ្ទាត់ $\hat{v} \neq 0$ អនុវត្ត $v \mapsto \hat{v}$ គឺពហុវចនៈនិងអ៊ីសូម៉ូភីស។

គេបាន $\dim V = \dim V^* = \dim V^{**}$ ព្រោះ $V$ មានវិមាត្រកំណត់។ យោងតាម អនុវត្ត $v \mapsto \hat{v}$ គឺជាអ៊ីសូម៉ូភីសនៃ $V$ លើ $V^{**}$ ។

៥.៨. បង្ហាញថាបើ $\phi \in V^*$ បំបែកសំណុំរង $S$ នៃ $V$ នោះ $\phi$ បំបែកលីនេអ៊ែរ ស្ប៉ាន $L(S)$ នៃ $S$ ។ នោះ $S^0 = \left[span(S)\right]^0$

សន្មតថា $v \in span(S)$ ។ គេមាន $w_1, ..., w_r \in S$ ដែល $v = a_1w_1 + a_2w_2 + ... + a_rw_r$

$\phi(v) = a_1\phi(w_1) + a_2\phi(w_2) + ... + a_r\phi(w_r) = a_1 0 + a_2 0 + ... + a_r 0 = 0$

ព្រោះ $v$ មានជាតុណាមួយនៃ $span(S)$ $\phi$ បំបែក $span(S)$ ។

៥.៩. រកគោលនៃបំបែក $W^0$ នៃលំហរង $W$ នៃ $\mathbb{R}^4$ ស្ប៉ានដោយ

$v_1 = (1,2,-3,4)$ និង $v_2 = (0,1,4,-1)$

តាមលំហាត់១១.៨. វាគ្រប់គ្រាន់ក្នុងការរកគោលនៃសំណុំអនុគមន៍លីនេអ៊ែរ $\phi$ ដែល $\phi(v_1) = 0$ និង $\phi(v_2) = 0$ ដែល $\phi(x_1, x_2, x_3, x_4) = ax_1 + bx_2 + cx_3 + dx_4$ ។ ដូច្នេះ

$\phi(1,2,-3,4) = a + 2b - 3c + 4d = 0$ និង $\phi(0,1,4,-1) = b = 4c - d = 0$

ប្រព័ន្ធនៃពីរសមីការក្នុងប៉ារ៉ាម៉ែត្រ $a,b,c,d$ គឺក្នុងទម្រង់echelon ជាមួយអថេរសេរី $c$ និង $d$

(1) កំណត់ $c = 1, d = 0$ គេបាន $a = 11, b = -4, c = 1, d = 0$

(2) កំណត់ $c = 0, d = 1$ គេបាន $a = 6, b = -1, c = 0, d = 1$

អនុគមន៍លីនេអ៊ែរ $\phi_1(x_i) = 11x_1 - 4x_2 + x_3$ និង $\phi_2(x_i) = 6x_1 - x_2 + x_4$ ជាគោលនៃ $W^0$ ។

៥.១០. បង្ហាញថា

i. សម្រាប់សំណុំរង $S$ នៃ $V, S \subseteq S^{00}$

តាង $v \in S$ នោះគ្រប់អនុគមន៍លីនេអ៊ែរ $\phi \in S^0$, $\hat{v}(\phi) = \phi(v) = 0$ ។ គេបាន $\hat{v} \in \left(S^0\right)^0$ ។ ដូចនេះ នៅក្រោមការកំណត់អត្តសញ្ញាណនៃ $V$ និង $V^{**}, v \in S^{00}$ ។ យោងតាម $S \subseteq S^{00}$ ។

ii. បើ $S_1 \subseteq S_2$ នោះ $S_2^0 \subseteq S_1^0$

តាង $\phi \in S_2^0$ នោះ $\phi(v) = 0$ គ្រប់ $v \in S_2$ ប៉ុន្តែ $S_1 \subseteq S_2$ គេបាន $\phi$ បំបែកគ្រប់ធាតុនៃ $S_1$ ដូចនេះ $S_2^0 \subseteq S_1^0$ ។

៥.១១. ស្រាយបញ្ជាក់ទ្រឹស្តីបទ១១.៥។ សន្មតថា $V$ មានវិមាត្រកំណត់និង $W$ គឺជាលំហរងនៃ $V$ ។ គេបាន

i. $\dim W + \dim W^0 = \dim V$

សន្មតថា $\dim V = n$ និង $\dim W = r \le n$ ។ យើងនឹងបង្ហាញថា $\dim W^0 = n - r$ ។ យើងជ្រើសរើសគោល $\{w_1,...,w_r\}$ នៃ $W$ និងពង្រីកវាទៅជាគោលនៃ $V$ ដែល $\{w_1,...,w_r,v_1,...,v_{n-1}\}$ ។

ពិចារណាគោលឌុយអាល់ $\{\phi_1,...,\phi_r,\sigma_1,...,\sigma_{n-1}\}$

តាមនិយមន័យនៃគោលឌុយអាល់ គេបាន $\sigma_1,...,\sigma_{n-r} \in W^0$

យើងបាន $\{\sigma_i\}$ គឺជាគោលនៃ $W^0$ ។ នោះ $\{\sigma_j\}$ ជាផ្នែកនៃគោលមួយនៃ $V^*$ ហើយវាមិនអាស្រ័យលីនេអ៊ែរ។

បន្ទាប់មកយើងបង្ហាញថា $\{\phi_j\}$ ស្ប៉ាន $W^0$ ។ តាង $\sigma \in W^0$ តាមទ្រឹស្តីបទ១១.២

$$\begin{aligned}\sigma &= \sigma(w_1)\phi + ... + \sigma(w_r)\phi_r + \sigma(v_1)\sigma_1 + ... + \sigma(v_{n-r})\sigma_{n-r}\\ &= 0\phi + ... + 0\phi_r + \sigma(v_1)\sigma_1 + ... + \sigma(v_{n-r})\sigma_{n-r}\\ &= \sigma(v_1)\sigma_1 + ... + \sigma(v_{n-r})\sigma_{n-r}\end{aligned}$$

គេបាន $\{\sigma_1,...,\sigma_{n-1}\}$ ស្ប៉ាន $W^0$ ហើយវាជាគោលនៃ $W^0$ ។ នាំឱ្យ

$$\dim W^0 = n - r = \dim V - \dim W$$

ii. $W^{00} = W$

សន្មតថា $\dim V = n$ និង $\dim W = r$ ។ នោះ $\dim V^* = n$ និង $\dim W^0 = n - r$ ។ គេបាន $\dim W^{00} = n - (n-r) = r$ ដូចនេះ $\dim W = \dim W^{00}$ ។ តាមលំហាត់១១.១០ $W \subseteq W^{00}$ ផ្អែកតាម $W = W^{00}$ ។

៥.១២. តាង $U$ និង $W$ ជាលំហរងនៃ $V$ ។ បង្ហាញថា $(U+W)^0 = U^0 \cap W^0$ ។

តាង $\phi \in (U+W)^0$ ។ នោះ $\phi$ បំប្លែងជា $U+W$ និងជាទូទៅ $\phi$ បំប្លែង $U$ និង $W$ ។ គេបាន $\phi \in U^0$ និង $\phi \in W^0$ គេបាន $\phi \in U^0 \cap W^0$ ។ ដូចនេះ $(U+W)^0 = U^0 \cap W^0$ ។

ម្យ៉ាងវិញទៀត សន្មតថា $\sigma \in U^0 \cap W^0$ ។ គេបាន $\sigma$ បំប្លែងជា $U$ និង $W$ ។ បើ $v \in U + W$ នោះ $v = u + w$ ដែល $u \in U$ និង $w \in W$ ។ ដូចនេះ $\sigma(v) = \sigma(u) + \sigma(w) = 0 + 0 = 0$ ។ គេបាន $\sigma$ បំប្លែង $U+W$ ដែល $\sigma \in (U+W)^0$ ។ ដូចនេះ $(U+W)^0 = U^0 \cap W^0$ ។

៥.១៣. តាង $\phi$ ជាអនុគមន៍លីនេអ៊ែរលើ $\mathbb{R}^2$ កំណត់ដោយ $\phi(x,y) = x - 2y$ ។

ប្រមាណវិធីលីនេអ៊ែរ $T$ លើ $\mathbb{R}^2$ រក $(T^t(\phi))(x,y)$

a. $T(x,y) = (x,0)$

$(T^t(\phi))(x,y) = \phi(T(x,y)) = \phi(x,0) = x$

b. $T(x,y) = (y, x+y)$

$(T^t(\phi))(x,y) = \phi(T(x,y)) = \phi(y,x+y) = y - 2(x+y) = -2x - y$

c. $T(x,y)=(2x-3y,5x+2y)$ តាមន័យនិយមន័យ $T^t(\phi)=\phi\circ T$ ដែល

$(T^t(\phi))(v)=\phi(T(v))$ សម្រាប់គ្រប់ $v$

$(T^t(\phi))(x,y)=\phi(T(x,y))=\phi(2x-3y,5x+2y)=(2x-3y)-2(5x+2y)=-8x-7y$

៥.១៤. តាង $T:V\to U$ គឺលីនេអ៊ែរ និងតាង $T^t:U^*\to V^*$ គឺត្រង់ស្ប៉ូ។ បង្ហាញថា *Kernel* នៃ $T^t$ គឺបំប្លែងរូបភាពនៃ $T$ ដែល $Ker\ T^t=(\operatorname{Im}T)^0$ ។

សន្មតថា $\phi\in\ker T^t$ ដែល $T^t(\phi)=\phi\circ T=0$ ។ បើ $u\in\operatorname{Im}T$ នោះ $u=T(v)$ សម្រាប់គ្រប់ $u\in V$ នោះ $\phi(u)=\phi(T(v))=(\phi\circ T)(v)=0(v)=0$

យើងមាន $\phi(u)=0$ សម្រាប់គ្រប់ $u\in\operatorname{Im}T$ នោះ $\phi\in(\operatorname{Im}T)^0$ ។ ដូច្នេះ $Ker\ T^t\subseteq(\operatorname{Im}T)^0$ ។

ម្យ៉ាងទៀត សន្មតថា $\sigma\in(\operatorname{Im}T)^0$ ដែល $\sigma(\operatorname{Im}T)=\{0\}$ ។ នោះ គ្រប់ $u\in V$

$$(T^t(\sigma))(v)=(\sigma\circ T)(v)=\sigma(T(v))=0=0(v)$$

យើងមាន $(T^t(\sigma))(v)=0(v)$ សម្រាប់គ្រប់ $u\in V$ នោះ $T^t(\sigma)=0$ ។ ដូច្នេះ $\sigma\in\ker T^t$ និង $(\operatorname{Im}T)^0\subseteq\ker T^t$ ។

ទំនាក់ទំនងទាំងពីរគឺស្មើគ្នា។

៥.១៥. សន្មតថា $V$ និង $U$ មានវិមាត្រកំណត់ និង $T:V\to U$ គឺលីនេអ៊ែរ។

បង្ហាញថា $rank(T)=rank(T^t)$

សន្មតថា $\dim V=n$ និង $\dim U=m$ ហើយសន្មតថា $rank(T)=r$ តាមទ្រឹស្តីបទ១១.៥

$$\dim(\operatorname{Im}T)^0=\dim u-\dim(\operatorname{Im}T)=m-rank(T)=m-r$$

ដោយលំហាត់១១.១៤ $KerT^t=(\operatorname{Im}T)^0, nullity(T^t)=m-r$

$$rank(T^t)=\dim U^*-nullity(T^t)=m-(m-r)=r=rank(T)$$

៥.១៦. ស្រាយបញ្ជាក់ទ្រឹស្តីបទ១១.៧ តាង $T:V\to U$ គឺលីនេអ៊ែរ និងតាង $A$ គឺជាម៉ាទ្រីសនៃ $T$ ក្នុងគោល $\{v_j\}$ នៃ $V$ និង $\{u_i\}$ នៃ $U$ ។ នោះម៉ាទ្រីសត្រង់ស្ប៉ូ $A^T$ គឺជាម៉ាទ្រីសនៃ $T^t:U^*\to V^*$ ក្នុងគោលឌុយអាល់ $\{u_i\}$ និង $\{v_j\}$ ។

សន្មតថា សម្រាប់ $j=1,...,m,$

$$T(v_j)=a_{j1}u_1+a_{j2}u_2+...+a_{jn}u_n \qquad (1)$$

យើងចង់បង្ហាញសម្រាប់ $i=1,...,n,$

$$T^t(\sigma_i)=a_{1i}\phi_1+a_{2i}\phi_2+...+a_{mi}\phi_m \qquad (2)$$

ដែល $\{\sigma_i\}$ និង $\{\phi_j\}$ គឺជាគោលឌុលអាល់ $\{u_i\}$ និង $\{v_j\}$ ។

តាង $u\in V$ និងសន្មតថា $v=k_1v_1+k_2v_2+...+k_mv_m$ តាម $(1)$ គេបាន

$$
\begin{aligned}
T(v) &= k_1T(v_1)+k_2T(v_2)+...+k_mT(v_m)\\
&= k_1(a_{11}u_1+...+a_{1n}u_n)+k_2(a_{21}u_1+...+a_{2n}u_n)+...+k_m(a_{m1}u_1+...+a_{mn}u_n)\\
&= (k_1a_{11}+k_2a_{21}+...+k_ma_{m1})u_1+...+(k_1a_{1n}+k_2a_{2n}+...+k_ma_{mn})u_n\\
&= \sum_{i=1}^{n}(k_1a_{1i}+k_2a_{2i}+...+k_ma_{mi})u_i
\end{aligned}
$$

ម្យ៉ាងទៀត សម្រាប់ $j=1,...,n$

$$
\begin{aligned}
\left(T^t(\sigma_j)(v)\right) &= \sigma_j\left(T(v)\right)=\sigma_j\left(\sum_{i=1}^{n}(k_1a_{1i}+k_2a_{2i}+...+k_ma_{mi})u_i\right)\\
&= k_1a_{1j}+k_2a_{2j}+...+k_ma_{mj} \qquad (3)
\end{aligned}
$$

មួយវិញទៀត សម្រាប់ $j=1,...,n$

$$
\begin{aligned}
(a_{1j}\phi_1+a_{2j}\phi_2+...+a_{mj}\phi_m)(v) &= (a_{1j}\phi_1+a_{2j}\phi_2+...+a_{mj}\phi_m)(k_1v_1+k_2v_2+...+k_mv_m)\\
&= k_1a_{1j}+k_2a_{2j}+...+k_ma_{mj} \qquad (4)
\end{aligned}
$$

ដូចនេះ $T^t(\sigma_j)=a_{1j}\phi_1+a_{2j}\phi_2+...+a_{mj}\phi_m,\ \ j=1,...,n$ ។

ឯកសារយោង


1. វចនានុក្រម គណិតវិទ្យា អង់គ្លេស-ខ្មែរ ,RUPP (2017)
2. វចនានុក្រម សម្តេចសង្ឃ ជួន ណាត
3. សៀវភៅពីជគណិតលីនេអ៊ែរ សកលវិទ្យាល័យភូមិន្ទភ្នំពេញ(២០១៣)
4. ឯកសាររបស់ ពីជគណិតលីនេអ៊ែរ លោកស្រីបណ្ឌិត ឡឹង រដ្ឋា (២០២៣)
5. សៀវភៅ ពីជគណិតលីនេអ៊ែរ
6. Álgebra lineal - Eduardo Espinoza Ramos
7. Algebra 1_McGraw-Hill.pdf ( PDFDrive.com )
8. Hogben-Handbook of Linear Algebra-(CRC press, 2007)
9. Linear_Algebra,_4th_Edition__(2009)Lipschutz-Lipson
10. Linear Algebra and Its Applications 4E (Lay).
11. howard_anton_chris_rorres_elementary_linear_algebra_applications_version_11th_edition
12. Linear Algebra
13. David Cherney, Tom Denton,Rohit Thomas and Andrew Waldron: Edited by Katrina Glaeser and Travis Scrimshaw,First Edition. Davis California, 2013